ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង

# របាយការណ៍
# ស្តីពីវឌ្ឍនភាព និងទិសដៅការងារបន្ត
# របស់រដ្ឋបាលខេត្តស្វាយរៀង
# (២០១៨-២០២២)

សន្និសីទសារព័ត៌មាន ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

## I. **ស្ថានភាពទូទៅរបស់ខេត្តស្វាយរៀង**

ជាដំបូង ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ និងប្រជាពលរដ្ឋ ក្នុងខេត្តស្វាយរៀងទាំងមូល **សូមអរគុណសន្តិភាព «បើគ្មានសន្តិភាព ក៏គ្មានអ្វីៗដូចសព្វថ្ងៃនេះដែរ»** ជាពិសេស សូមគោរពអរគុណ ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ដែលជាស្ថាបនិក នៃសន្តិភាព ។

### ១. **អំពីប្រវត្តិនៃការបង្កើតខេត្តស្វាយរៀង**

យោងតាមការសិក្សាស្រាវជ្រាវរបស់រដ្ឋបាលខេត្ត ក្រោមការដឹកនាំរបស់ **ឯកឧត្តមអភិបាលខេត្ត** បានឱ្យដឹងថា ខេត្តស្វាយរៀង ត្រូវបានបង្កើតឡើងដោយព្រះរាជប្បញ្ញត្តិលេខ ៤៩ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩២២ ក្នុងរជ្ជកាល **ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ** ដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូលគ្នា នៃខេត្ត ចំនួន៣ គឺ ខេត្តរំដួល ខេត្តមោសហៃក និងខេត្តស្វាយទាប ។

### ២. **អំពីនិមិត្តសញ្ញាខេត្តស្វាយរៀង**

និមិត្តសញ្ញាខេត្តស្វាយរៀង ត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមប្រកាសលេខ ២១០៩ ប្រ.ក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ។ និមិត្តសញ្ញាខេត្តស្វាយរៀង មាន **រាងមូល** មានរូប **ព្រះគោនន្ទី** តំណាងឱ្យភាពត្រជាក់ត្រជុំ សំបូរសប្បាយ សេចក្តីសុខ សីល្បៈវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខេត្តស្វាយរៀង មាន**បាច់កួរស្រូវពណ៌មាស** តំណាងឱ្យភោគផលកសិកម្ម ការរួបរួមសាមគ្គី មាន **ខ្សែបូពណ៌ក្រហមខៀវ** តំណាងឱ្យអត្តសញ្ញាណជាតិខ្មែរ **ផ្ទៃខាងក្រោយពណ៌ផ្ទៃមេឃស្រាល** តំណាងឱ្យទន្លេវៃគោ ជាប្រភពទឹកសម្រាប់បម្រើដល់ការងារផលិតកម្មកសិកម្ម និងជាកន្លែងបង្កើតពូជត្រី និង**កាំកង់ចក្រ** តំណាងឱ្យវិស័យឧស្សាហកម្ម ដែលបច្ចុប្បន្ន ខេត្តស្វាយរៀង មានតំបន់សេដ្ឋកិច្ចពិសេស មានរោងចក្រ សហគ្រាស កំពុងដំណើរការជាច្រើនកន្លែង ដែលបានបង្កើតការងារធ្វើជូនប្រជាពលរដ្ឋ ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងពង្រឹងកំណើនសេដ្ឋកិច្ច ។

### ៣. **ភូគោលវិទ្យា ភូមិសាស្ត្រ និងប្រជាសាស្ត្រ**

ខេត្តស្វាយរៀង គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង ២៥ ស្ថិតនៅប៉ែកអាគ្នេយ៍ មានចម្ងាយប្រមាណ ១២៥ គ.ម ពីរាជធានីភ្នំពេញ ដែលមានផ្លូវជាតិលេខ១ ឆ្លងកាត់ប្រវែង ៦៥ គីឡូម៉ែត្រ មានព្រំប្រទល់ខាងជើង និងខាងលិចជាប់នឹងខេត្តព្រៃវែង ខាងកើត និងខាងត្បូងជាប់នឹងខេត្ត តៃនិញ និងខេត្តឡុងអាន ប្រទេសវៀតណាម ។ ខេត្តមានផ្ទៃដីរួម ២.៩៦៦,៤០ គីឡូម៉ែត្រក្រឡា ចែកចេញជា ២ក្រុង ៦ស្រុក ៦៨ឃុំ ១២សង្កាត់ ៦៩០ភូមិ មានប្រជាពលរដ្ឋសរុបចំនួន ៦៧៤.៦៣៥នាក់ ស្រី ៣៤៦.៥១១នាក់ ស្មើនឹង ១៦០.៦១១គ្រួសារ ប្រជាពលរដ្ឋ អាយុ ១៨ឆ្នាំឡើង មាន ៤៣៨.០៩៥នាក់ ស្រី ២២៥.៥៩៤នាក់ ក្នុងនោះប្រជាជនអាយុ ១៨ឆ្នាំឡើងដែលមានការងារធ្វើមានចំនួន ៩២,៦% មានដង់ស៊ីតេប្រជាជន មានចំនួន ២២៤នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ក្នុងអត្រាកំណើនប្រចាំឆ្នាំប្រមាណ ១,៧% ។

ចំពោះទំហំសេដ្ឋកិច្ច (GDP) ខេត្តស្វាយរៀង មានចំនួន ១.០៩៤.៦១៦.៩២៥ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ២០២១ បានបង្ហាញថា ខេត្តស្វាយរៀង មានកំណើនសេដ្ឋកិច្ច ៥,៦% ក្នុងនោះ បានចូលរួមចំណែកពីវិស័យកសិកម្ម ប្រមាណជា ៤៣,៧៦% វិស័យឧស្សាហកម្ម ប្រមាណជា ៣៨,១២% និងវិស័យសេវាកម្ម ប្រមាណជា ១៨,១២% ។ ចំណូលសម្រាប់មនុស្សម្នាក់ មានប្រមាណ ១.៥៩៥ដុល្លារអាម៉េរិក កើនឡើង ២៦៧ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ២០១៨ ។

ខេត្តស្វាយរៀង មានច្រកទ្វារព្រំដែនចំនួន ៨កន្លែង រួមមាន ច្រកទ្វារព្រំដែនអន្តរជាតិ ២កន្លែង ច្រកទ្វារព្រំដែនទ្វេភាគី ២កន្លែង និងច្រកទ្វារតំបន់ព្រំដែន ៤កន្លែង និងមានកំពង់ផែ ០១កន្លែង ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការដោះដូរពាណិជ្ជកម្ម កសិផលផ្សេងៗ និងការធ្វើដំណើរឆ្លងកាត់ព្រំដែន របស់ប្រជាពលរដ្ឋ ក្នៀវជាតិ អន្តរជាតិ ។

បច្ចុប្បន្នខេត្ត បានរៀបចំសំណើទៅរាជរដ្ឋាភិបាល ដើម្បីស្នើសុំបង្កើតច្រកទ្វារតំបន់ព្រំដែនមួយកន្លែងទៀត គឺច្រកទ្វារតំបន់ព្រំដែនក្រសាំងជ្រំ ស្ថិតនៅភូមិក្រសាំងជ្រំ ឃុំគ្រួស ស្រុកស្វាយជ្រំ ។

## II. **រចនាសម្ព័ន្ធរដ្ឋបាលខេត្ត**

អនុវត្តតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលខេត្តស្វាយរៀង មានរចនាសម្ព័ន្ធ គឺមានក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត នាយករដ្ឋបាល ទីចាត់ការ ៥ អង្គភាព ២ និងការិយាល័យ ១៦ និងមានមន្ទីរ-អង្គភាពជំនាញ ជាសេនាធិការ ដែលស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ។

## III. **វឌ្ឍនភាពរបស់ខេត្តស្វាយរៀង**

កត្តាសុខសន្តិភាព ស្ថិរភាពនយោបាយល្អប្រសើរ រឹងមាំនៅក្នុងក្របខណ្ឌទូទាំងប្រទេស តាមរយៈនយោបាយឈ្នះឈ្នះ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាប្រមុខដឹកនាំ ប្រកបដោយគតិបណ្ឌិត រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅកសាងមូលដ្ឋាន ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ប្រទេសកម្ពុជាជាប្រទេស ដែលមានចំណូលខ្ពស់ ។

ផ្អែកលើកត្តាសុខសន្តិភាព និងមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល បានធ្វើឱ្យខេត្តស្វាយរៀង មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ជាពិសេសក្រោមការដឹកនាំ ចង្អុលបង្ហាញរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** រដ្ឋបាលខេត្តស្វាយរៀង ក្រោមការដឹនាំរបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ជាពិសេស **ឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត** ដោយមានកងកម្លាំងទាំង៣ ជាសេនាធិការ បានខិតខំយកចិត្ត ទុកដាក់ក្នុងថែរក្សាសុខសន្តិភាព

សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការអនុវត្តជាប្រចាំនូវគោលនយោបាយភូមិឃុំ សង្កាត់មានសុវត្ថិភាព បានធ្វើឱ្យសភាពការណ៍ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានលក្ខណៈល្អប្រសើរ ធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ប្រកបដោយសេចក្តីសុខសាន្ត ជាពិសេសធានាដល់ដំណើរការ នៃការអភិវឌ្ឍខេត្ត ឱ្យមានរីកចម្រើន សំដៅលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើង ។

សូមជម្រាបជូនថា ចំពោះការប្រឡងប្រណាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ក្នុងឆ្នាំ២០២២កន្លងទៅ ខេត្តស្វាយរៀង បានរៀបចំវេទិកាសាធារណៈ ចំនួន ៣.៣១១លើក មានអ្នកចូលរួម ១០៤.៨៦៤នាក់ ។ ឃុំ សង្កាត់ ដែលទទួលបាន ចំណាត់ថ្នាក់លេខ១ ចំនួន ៧៨ឃុំ-សង្កាត់ លេខ២ ចំនួន ០២ឃុំ លេខ៣ (គ្មាន) និងមិនមានឃុំ សង្កាត់ដែលមិនទទួលបានចំណាត់ថ្នាក់នោះទេ ។

ក្នុងរយៈពេល ៥ឆ្នាំនេះ ការងារប្រឆាំងបទល្មើសគ្រឿងញៀន សមត្ថកិច្ច បានធ្វើការបង្ក្រាបចំនួន ៥៨៨លើក ឃាត់ខ្លួនមនុស្សចំនួន ១.៣៧៨នាក់ ស្រី ៧៤នាក់ ដកហូតវត្ថុតាងរួមមាន៖ ម្សៅក្រាមពណ៌សថ្លា ប្រភេទមេតំហ្វេតាមីនទម្ងន់ ១.២២៦,៥៨តោន(គិតទាំងសំបកវេចខ្ចប់) ថ្នាំគ្រាប់អក្សរ D ទម្ងន់ ៦,៧៦ក្រាម ថ្នាំគ្រាប់ WY ទម្ងន់ ០,៤៧ក្រាម ថ្នាំដប Dr.Padesa ១៥ដប ថ្នាំParis ១កញ្ចប់ ហេរ៉ូអ៊ីនទម្ងន់ ១៨.៦៩៤,៨៦ក្រាម (គិតទាំងសំបកវេចខ្ចប់) ថ្នាំគ្រាប់ពណ៌ផ្ទៃមេឃទម្ងន់ ១០៤,៩ក្រាម ថ្នាំគ្រាប់ពណ៌ទឹកក្រូចទម្ងន់ ១៩២,៨ក្រាម ថ្នាំគ្រាប់ពណ៌ផ្កាឈូក ១០៤,០៥ក្រាម ថ្នាំគ្រាប់ពណ៌សទម្ងន់ ១០គ្រាប់ កញ្ឆា ៥កញ្ចប់ ម្សៅ K ១កញ្ចប់ អិចស្តាស៊ីពណ៌ផ្កាឈូកទម្ងន់ ៤៣.៦៤៧,២២ក្រាម (គិតទាំងសំបកវេចខ្ចប់) កាំភ្លើង ៤ដើម វត្ថុធាតុផ្សំ ២១មុខ និង ៧ដប រថយន្ត ១៨គ្រឿង ម៉ូតូ ៣៨០គ្រឿង ទូរស័ព្ទដៃ ១.២០៦គ្រឿង និងថវិកាមួយចំនួន ។

អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងផ្អែកលើផែនការអភិវឌ្ឍខេត្ត រយៈពេល ៥ឆ្នាំ (២០១៩-២០២៣) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត (២០២០-២០២២) រដ្ឋបាលខេត្តស្វាយរៀង ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាខេត្ត ជាពិសេស **ឯកឧត្តមអភិបាលខេត្ត** បានខិតខំធ្វើការអភិវឌ្ឍខេត្ត ក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន ឱ្យមានការរីកចម្រើន លើគ្រប់វិស័យ ដោយបានកំណត់តំបន់សក្តានុពលរបស់ខេត្ត ជា ០៣តំបន់ រួមមាន តំបន់ផលិតកម្មកសិកម្ម តំបន់កសិ-ឧស្សាហកម្ម និងតំបន់ឧស្សាហកម្ម ។

### ១. អំពីកិច្ចសហប្រតិបត្តិការ

អនុវត្តតាមកិច្ចព្រមព្រៀង សន្ធិសញ្ញា អនុសញ្ញា រវាងប្រទេសទាំងពីរ (កម្ពុជា-វៀតណាម) រដ្ឋបាលខេត្តស្វាយរៀង នៃព្រះរាជាណាចក្រកម្ពុជា និងខេត្តឡុងអាន ខេត្តតៃនិញ នៃ

សាធារណរដ្ឋសង្គមនិយមវៀតណាម បានបន្តខិតខំពង្រឹងចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការ ដោយផ្អែកលើស្មារតីគោរព អធិបតេយ្យភាព បូរណភាពទឹកដី ផលប្រយោជន៍ និងការគាំទ្រគ្នាទៅវិញទៅមក ក្រោមបាវចនា «**ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង**» ។ ជាមួយគ្នានេះភាគីទាំងពីរ បានខិតខំជំរុញកិច្ចសហប្រតិបត្តិការ ក្នុងការគ្រប់គ្រងព្រំដែន ដោយផ្អែកលើយន្តការ និងក្របខណ្ឌច្បាប់ ដែលមានជាធរមាន ដើម្បីកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព ស្ថិរភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាព ។

## ២. ការងារអភិវឌ្ឍន៍ ដោយប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត

ចំពោះការអនុវត្តថវិកាគុណប្រយោជន៍ខេត្ត ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះ រដ្ឋបាលខេត្ត ក្រោមការដឹកនាំរបស់ **ឯកឧត្តមអភិបាលខេត្ត** សម្រេចបានលទ្ធផល ដូចខាងក្រោម ៖

- នៅក្នុងឆ្នាំ២០១៨ រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

-បានជួសជុលការ៉ូឡាអមសងខាងផ្លូវ និងទីធ្លាសាលាខេត្ត

-បានជួសជុលលូទឹកស្អុយ លូមូល និងជ្រុងចំនួន ០៧ខ្សែ ប្រវែង ៣.២៥៥ម និងរ៉េហ្គាចំនួន ១០០កន្លែង

-បានសាងសង់សាលាឃុំចំនួន ៨កន្លែង

-បានដាក់ភ្លើងស្តុបចំនួន ០២កន្លែង ក្នុងក្រុងស្វាយរៀង

-បានជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន ០២ខ្សែ ប្រវែង ៤.២០៧ម

-បានជួសជុលផ្លូវអ៊ុតបេទីមAC ចំនួន ០៦ខ្សែ មានក្រឡាផ្ទៃសរុប ២០.១២២,៥ម$^{២}$

-បានជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន ០៤ខ្សែ

- នៅក្នុងឆ្នាំ២០១៩ រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

-បានកែលម្អប្រាំងទន្លេវ៉ៃគោប្រវែង ២០៥ម ទទឹង ៣,២ម

-បានជួសជុលប័រឡៃចិញ្ចើមផ្លូវប្រវែង ១.១០៦ម និងក្រាលឥដ្ឋការ៉ូឡាចំនួន ៣.៧២០ម$^{២}$

-បានជួសជុលផ្លូវបេតុង ឆ្អឹងដែក និងចាក់សាបបេតុងឆ្អឹងដែក ដែលមាន ផ្ទៃក្រឡាសរុប ១.៨១៦ម២ នៅសង្កាត់ស្វាយរៀង

-បានជួសជុលក្លោងទ្វារសាលាខេត្តប្រវែង ១២ម ទទឹង ២,២ម កម្ពស់ ៦,៨៦ម និងជួសជុលរបងជុំវិញសាលាខេត្ត ប្រវែង ៤៣២ម កម្ពស់ ៣,៤០ម

-បានជួសជុលលូរំដោះទឹកមុខកាត់ ០,៤ម ប្រវែង ៣៥៨ម និងរ៉ឺហ្គាចំនួន ៣៥កន្លែង និងលូមុខកាត់ ០,៦ម ប្រវែង ១.៣៩៨ម រ៉េហ្គា ៧២កន្លែង នៅសង្កាត់ស្វាយរៀង និងសង្កាត់ស្វាយតឿ

-បានជួសជុលផ្លូវខ្សាច់ក្រហមប្រវែង ៦.៨៥០ម ទទឹង ៥ម នៅឃុំស្វាយរំពារ ស្រុកស្វាយទាប និងឃុំពងទឹក ស្រុករំដួល

-បានសាងសង់សាលាឃុំ សង្កាត់ចំនួន ១០ខ្នង

-បានជួសជុលស្ពានបាឡេចំនួន ០៣កន្លែង

-បានជួសជុលបណ្តាញអគ្គិសនីសាធារណៈ

-បានជួសជុលអាគារអង្គភាពច្រកចេញចូលតែមួយសាលាខេត្ត និងការិយាល័យក្រុមប្រឹក្សាខេត្ត

-បានជួសជុលបន្ទប់សាលសាលាខេត្ត

-បានជួសជុលជួសផ្សារកំពង់រោទិ៍ដោយប្តូរដំបូល ដែរណែង ទរទឹកថ្មី និងលាបថ្នាំ

-បានជួសជុលកំណាត់ផ្លូវលេខ ១០៥ ដោយក្រាលខ្សាច់ក្រហម

-បានជួសជុលលូរំដោះទឹក ដោយដាក់រ៉ែហ្គាតូច ៣៥កន្លែង និងរ៉ែហ្គាធំ ៣៤កន្លែង ដែលមានទឹកប្រាក់ ១០៣.៤៨៤.០០០រៀល ។

-បានជួសជុលផ្លូវលេខ១០៥ ប្រវែង ១៨០ម ទទឹង ៦ម និងដាក់លូមុខកាត់ ៤,៤ម នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ដែលមានទឹកប្រាក់ ៤៥៥.៨៤០.០០០រៀល ។

-បានជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន ០២ខ្សែ ប្រវែង ១.៦១០ម ស្ថិតនៅសង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ដែលមានទឹកប្រាក់ ៩៧០.៥០០.០០០រៀល ។

-បានជីកស្រះ ធ្វើស្ពានឆ្លងស្រះ និងរៀបការឡើ នៅរមណីយដ្ឋានប្រាសាទព្រៃបាសាក់ ដែលមានទឹកប្រាក់ ៣.៩៤២.០០០.០០០រៀល ។

-បានសាងសង់អាគារច្រកចេញចូលតែមួយក្នុងសាលាស្រុករមាសហែក ដែលមានទឹកប្រាក់ ៤១៨.៦៧៨.៤០០រៀល ។

-បានជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន ០៥ខ្សែ ប្រវែង ៥.៨២៦ម ស្ថិតនៅសង្កាត់បាវិត ក្រុងបាវិត ដែលមានទឹកប្រាក់ ៧.៩៨០.០០០.០០០រៀល ។

-បានជួសជុលស្ពានបាឡេចំនួន ០៣កន្លែង នៅឃុំគោកព្រីង ស្រុកស្វាយជ្រំ ឃុំសំបួរ ស្រុកស្វាយទាប និងសង្កាត់សង្ឃរ័ ក្រុងស្វាយរៀង ប្រវែងសរុប ៧៥ម ដែលមានទឹកប្រាក់សរុបចំនួន ៤៤៤.៦០០.០០០រៀល ។

-បានជួសជុលស្ពានបេតុងពោធិ៍តាហោ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ប្រវែង ៧២ម ដែលមានទឹកប្រាក់សរុបចំនួន ៥.៤៨៥.០០០.០០០រៀល ។

- នៅក្នុងឆ្នាំ២០២០ រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

-បានជួសជុលច្រាំងទន្លេដោយបុកគ្រឹះចាក់បេតុងធ្វើច្រាំងប្រវែង ៥៤០ម៉ ស្មើនឹងទឹកប្រាក់ ៦.៤៧២.៦០០.០០០៛ នៅក្រុងស្វាយរៀង ។

-បានជួសជុលផ្លូវបេតុងធ្មឹងដែក ខាងត្បូង ខាងជើង និងខាងលិចផ្សារពោធិ៍តាហោ ប្រវែង ១៨០ម៉ ។

-បានជួសជុលរបងខាងកើតពន្ធនាគារខេត្ត ប្រវែង ៨៧ម៉ កម្ពស់ ២,៣០ម៉ ក្នុងសង្កាត់ស្វាយរៀង ។

-បានជួសជុលថែទាំអគារ ក្នុងបរិវេណសាលាខេត្ត ស្មើនឹងទឹកប្រាក់ ១៧៣.000.000៛ ។

-បានជួសជុលផ្លូវចាក់បេតុងធ្មឹងដែកប្រវែង ៩៧០ម៉ ស្មើនឹងទឹកប្រាក់ ៥៧២.000.000៛ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ។

-បានជួសជុលផ្លូវចាក់បេតុងធ្មឹងដែកប្រវែង ២៣២ម៉ ស្មើនឹងទឹកប្រាក់ ៣១៨.១00.000៛ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។

-បានជួសជុលលូជ្រុងរំដោះទឹកភ្លៀងស្របប្រាំងទន្លេវៃគោប្រវែង ១.០១៥ម៉ ស្មើនឹងទឹកប្រាក់ ៥៩១.៥00.000៛ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។

-បានដាក់លូមុខកាត់ 0.៦0ម៉ ប្រវែង ២៣0ម៉ ស្មើនឹងទឹកប្រាក់ ១១១.000.000៛ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។

-បានជួសជុលលូមុខកាត់ 0.៦0ម៉ ប្រវែង ៦00ម៉ ស្មើនឹងទឹកប្រាក់ ២៨៤.៤00.000៛ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ។

-បានជួសជុលលូមុខកាត់ 0.៦0ម៉ ប្រវែង ៦៣២ម៉ ដាក់រ៉េហ្គា ៣២កន្លែង ស្មើនឹងទឹកប្រាក់ ២៩២.៧00.000៛ នៅសង្កាត់សង្ឃរ័ ក្រុងស្វាយរៀង ។

-បានជួសជុលលូមុខកាត់ 0.៦0ម៉ ប្រវែង ១៧៨ម៉ ដាក់រ៉េហ្គា ៩កន្លែង ស្មើនឹងទឹកប្រាក់ ៨៤.៣00.000៛ ។

-បានជួសជុលលូមុខកាត់ 0.៦0ម៉ ប្រវែង ៥៩ម៉ ដាក់រ៉េហ្គា ២កន្លែង ស្មើនឹងទឹកប្រាក់ ២៩.៨00.000៛ បណ្តោយផ្លូវលេខ ២១៤ ។

-បានចាក់ដីបំពេញ និងរៀបការ៉ូឡាសួនរមណីយដ្ឋានព្រៃបាសាក់ ស្ថិតនៅឃុំបាសាក់ ស្រុកស្វាយជ្រំ ស្មើនឹងទឹកប្រាក់ ៣.៦៨0.000.000៛ ។

-បានជួសជុលផ្លូវបេតុងធ្មឹងដែក រៀបខឿន និងប្រព័ន្ធលូ ក្នុងរមណីយដ្ឋានព្រៃបាសាក់ ស្ថិតនៅឃុំបាសាក់ ស្រុកស្វាយជ្រំ ស្មើនឹង ៣២0.000.000៛ ។

➢ នៅក្នុងឆ្នាំ២០២១ រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

-បានកែលម្អប្រាំងទន្លេវៃគោ តាមបណ្តោយផ្លូវលេខ២០១ ប្រវែង ៨១៥ម៉ែត្រ ។

-បានអភិវឌ្ឍន៍តំបន់ទេសចរណ៍រមណីយដ្ឋានប្រាសាទបាសាក់ (ព្រៃបាសាក់)

-បាបនការងាររុះរើការីឡាចាស់ប្រវែង ៣១០ម៉ ទទឹង ២,៥០ម៉ មានផ្ទៃ ៧៧៥ម² និង ការងាររៀបចំការីឡាថ្មីប្រវែង ៣១០ម៉ ទទឹង ០,៥០ម៉ មានផ្ទៃក្រឡា ១៥៥ម² ស្ថិតនៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង សរុបទឹកប្រាក់ចំនួន ១៨.៥០០.០០០រៀល ។

-បានជួសជុលលូរំដោះទឹកមុខកាត់ ០.៦០ម៉ ប្រវែង ១៦៤ម៉ មានរ៉ឺហ្គាចំនួន ០៩កន្លែង នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង សរុបចំនួនទឹកប្រាក់ ៧៧.៦០០.០០០រៀល ។

-បានជួសជុលផ្លូវលេខ១០៥ ក្រាលកៅស៊ូប្រភេទ DBST ប្រវែង ១៨០ម៉ ទទឹង ៦ម៉ មានផ្ទៃក្រឡាសរុប ១.០៨០ម២ នៅសង្កាត់ស្វាយរៀង សរុបទឹកប្រាក់ចំនួន ១៨៤.៤០០.០០០៛ ។

-បានជួសជុលកំណាត់ផ្លូវលេខ១០៧ ក្រាលកៅស៊ូប្រភេទ DBST ប្រវែង ១៧៦ម៉ ទទឹង ៩,៦២ម៉ មានផ្ទៃក្រឡាសរុប ១.៦៩៣ម² នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង សរុបទឹកប្រាក់ចំនួន ៣៤៦.៦០៤.០០០រៀល ។

-បានជួសជុលក្បាលឈ្នាងបេតុងឆ្អឹងដែកផ្លូវលេខ១២១ (រាងចតុកោណព្នាយ) ទំហំ ៦០,៣២ម² នៅសង្កាត់ស្វាយរៀង សរុបទឹកប្រាក់ចំនួន ១៦.៥០០.០០០រៀល ។

-បានជួសជុលលូមូលកាត់ផ្លូវមុខកាត់ ០.៦០ម៉ ប្រវែង ១.៣០៦ម៉ និងជួសជុលលូរំដោះទឹកមុខកាត់ ០.៦០ម៉ ប្រវែង ១៧៨ម៉ មានរ៉ឺហ្គាចំនួន ០៩កន្លែង នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង សរុបទឹកប្រាក់ចំនួន ៨៣.៩០០.០០០រៀល ។

-បានជួសជុលផ្លូវ ចំនួន ២ខ្សែ ដោយពង្រីកលើកកម្ពស់ផ្លូវ និងក្រាលគ្រួសក្រហម ប្រវែង ៤.២៥០ម៉ កម្រាស់ ០.២០ម៉ ខ្សែទី១ ប្រវែង ១.៥៥០ម៉ ទទឹង ៧ម៉ នៅឃុំសម្បត្តិមានជ័យ និងខ្សែទី២ ប្រវែង ២.៧០០ម៉ ទទឹង ៦ម៉ នៅឃុំម្រាម ក្នុងស្រុករមាសហែក សរុបទឹកប្រាក់ចំនួន ២.៩៨៥.០០០.០០០រៀល ។

-បានជួសជុលផ្លូវបេតុងឆ្អឹងដែកប្រវែង ៣៣០ម៉ ទទឹង ៦ម៉ កម្រាស់ ០.១៥ម៉ មានផ្ទៃក្រឡា ១.៩៨០ម² នៅសង្កាត់បាវិត ក្រុងបាវិត សរុបទឹកប្រាក់ចំនួន ២.៩៣៥.០០០.០០០៛ ។

-បានជួសជុលផ្លូវខេត្តចំនួន ១ខ្សែ ក្រាលគ្រួសក្រហមប្រវែង ២.៧៥០ម៉ ទទឹង ៥ម៉ នៅឃុំសម្បត្តិមានជ័យ ស្រុករមាសហែក សរុបចំនួនទឹកប្រាក់ ១.២៩៥.២៩៦.០០០រៀល។

-បានជួសជុលផ្លូវអ៊ុតកៅស៊ូបេទីមAC លើកំណាត់ផ្លូវលេខ ៣១៤ ប្រវែង ១.១២០ម៉ ទទឹង ១១ម៉ មានផ្ទៃក្រឡាសរុប ១២.៣២០ម² នៅសង្កាត់សង្ឃ័រ ក្រុងស្វាយរៀង សរុបទឹកប្រាក់ ចំនួន ៣.៦៧៩.៧០៤.០០០រៀល ។

-បានជួសជុលផ្លូវបេតុងឆ្អឹងដែក ចំនួន ១ខ្សែប្រវែង ១.៦៧០ម៉ ទទឹង ៨ម៉ កម្រាស់ ០.២០ម៉ មានផ្ទៃក្រឡា ១៣.៣៦០ម² សង្កាត់បាវិត ក្រុងបាវិត សរុបទឹកប្រាក់ចំនួន ៣.៧១៦.៧៨០.៣០០រៀល ។

-បានជួសជុលលូមូលកាត់ផ្លូវមុខកាត់ ០.៨០ម៉ ប្រវែង ៣៦៥ម៉ ទទឹង ៨ម៉ និងរីហ្គា ១៥កន្លែង តាមផ្លូវទៅកំពង់ស្ពាន បន្តពីលូចាស់ចាប់ពីចំណុច ៨៨៥ម៉ នៅសង្កាត់បាវិត ក្រុងបាវិត សរុបចំនួនទឹកប្រាក់ ២៧២.២១៩.៧០០រៀល ។

-បានជួសជុលបណ្តាញអគ្គិសនីសាធារណៈ ដោយប្តូរចង្កៀងគោម ខ្សែភ្លើងក្នុងក្រុងស្វាយរៀង សរុបទឹកប្រាក់ចំនួន ៤៤.៥៣៤.០០០រៀល ។

-បានសាងសង់អគាររដ្ឋបាលសង្កាត់ប្រាសាទ សាលាឃុំអណ្តូងពោធិ៍ និងសាលាឃុំរមាំងថ្កោល សរុបទឹកប្រាក់ចំនួន ១.០៥០.០០០.០០០រៀល ។

-បានជួសជុលលូរំដោះទឹកស្អុយមូលមុខកាត់ ប្រវែង ០.៦០ម៉ ប្រវែង ៩៦៤ម៉ រីហ្គា ៥០កន្លែង នៅសង្កាត់ស្វាយរៀង សរុបទឹកប្រាក់ចំនួន ៤៥២.៩០០.០០០៛ ។

-បានសាងសង់អគារច្រកចេញចូលតែមួយ ជូនរដ្ឋបាលស្រុកស្រុករំដួល និងស្រុកកំពង់រោទិ៍ ដែលមានបណ្តោយ ២០ម៉ ទទឹង ១៤ម៉ ព្រមទាំងបំពាក់សង្ហារឹម សរុបទឹកប្រាក់ចំនួន ៨៩៩.៤០០.០០០រៀល ។

- នៅក្នុងឆ្នាំ២០២២ រដ្ឋបាលខេត្តបានសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

-បានសាងសង់ការិយាល័យអង្គភាពច្រកចេញចូលតែមួយ ចំនួន ០៦ស្រុក ។

-បានសាងសង់សាលាសង្កាត់ពោធិ៍តាហោ សាលាឃុំក្រោលគោ និងអគារគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ។

-បានបញ្ចប់ការកែលម្អប្រាំងទន្លេវ៉ៃគោផ្នែកខាងជើង និងខាងត្បូង ។

-បានជួសជុលលូរំដោះទឹកស្អុយ មូលមុខកាត់ ០,៦០ម ប្រវែង ២៣៧៣ម រីហ្គា ៣២៦កន្លែង នៅក្រុងស្វាយរៀង ។

-បានជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ប្រវែង ២ ៨១១ម ក្នុងក្រុងស្វាយរៀង ។

-បានជួសជុលផ្លូវចាក់ដីពង្រឹក និងលើកកម្ពស់តួផ្លូវក្រាលគ្រួសក្រហមកម្រាស់ ០,២០មចំនួន ២ខ្សែ ប្រវែង ១.៩៥០ម ទទឹងខ្នងលើ ៥ម នៅឃុំសម្បត្តិមានជ័យ ស្រុករមាសហែក ។

-បានជួសជុលផ្លូវ (កំពង់ផែអូរស្នាច់) ដោយចាក់ដីពង្រឹក និងកំពស់តួថ្មល់ក្រាលខ្សាច់ភ្នំ និងថ្មម៉ិច M30 ចាក់បេតុងសរសៃដែកកម្រាស់ ០,២០មប្រវែង ៩៦០ម ទទឹង ៧ម នៅសង្កាត់គយត្របែក ។

-បានជួសជុលផ្លូវពង្រឹកគ្រឹះគ្រប់ស្រទាប់ដីសគ្រួសក្រហម និងថ្មម៉ិច រួចចាក់ពង្រឹកកៅស៊ូប្រភេទAC ចំនួន ០៥កំណាត់ ប្រវែង ៥៨៦០ម នៅក្រុងស្វាយរៀង។

-បានជួសជុលផ្លូវចាក់ដីសពង្រឹក និងលើកកម្ពស់តួផ្លូវ ក្រាលគ្រួសក្រហម និងចាក់ថ្មម៉ិច M30 កម្រាស់ ០,២០ម រួចចាក់បេតុងសរសៃដែកកម្រាស់ ០,១៥ម ប្រវែង ៩៧៥ម ទទឹងបេតុង ៨ម នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។

-បានចាក់ដីបំពេញទីតាំងទឹកលិចតំបន់រមណីយដ្ឋានប្រាសាទព្រៃបាសាក់(ព្រៃបាសាក់) បណ្តោយប្រវែង ១០២ម ទទឹង ៥០ម ជម្រៅ ៣,៤ម និងជួសជុលផ្លូវក្រាលខ្សាច់ភ្នំ ប្រវែង ៩៨០ ម នៅឃុំបាសាក់ ស្រុកស្វាយជ្រំ ។

-បានជួសជុលស្ពានបេតុងអាម៉េ ០១កន្លែង ប្រវែង ៣៦ម ទទឹង ១២ម ប្រវែងសរុប ៧២ ម នៅសង្កាត់ពោធិតាហោ ក្រុងស្វាយរៀង។

-បានជួសជុលផ្លូវអ៊ុតកៅស៊ូបេទីម AC ប្រវែង ២.១៦០ម ទទឹង ១១ម ទំហំ ២៣.៧៦០ម$^{២}$ កាយដីស្អុយចេញចាក់បំពេញដីល្អ ពង្រីកតួផ្លូវលើកកំពស់ផ្លូវ និងបន្ថែមគ្រឹះផ្លូវចាក់គ្រួសក្រហម និងថ្មម៉ិច លើកំណាត់ផ្លូវលេខ៣១៤ ពីក្បាលស្ពានតាហោទៅកើតប្រវែង ១.៩៦០ម

-បានជួសជុលផ្លូវខេត្ត ០១ខ្សែ ប្រវែង ១.៥៦០ម ទទឹង ៧ម កម្រាស់គ្រួស ០,២០ម និង ជួសជុលលូបេតុងកាត់ទទឹងផ្លូវមុខកាត់ ០,៦០ម (១ជួរ ៧ម) ចំនួន ០៦កន្លែង នៅឃុំសម្បត្តិមាន ជ័យ ស្រុករមាសហែក ។

-បានជួសជុលផ្លូវចាក់ដីលុបប្រឡាយសងខាងផ្លូវប្រវែង ១.៥៦០ម នៅឃុំម្រាម ។

-បានជួសជុលកាវីឡាសួនស្រះរង់ រុះរើកាវីឡាចាស់ចេញកែលម្អថ្មីឡើងវិញ នៅសង្កាត់ ស្វាយរៀង ក្រុងស្វាយរៀង ។

ដោយមានការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំខេត្ត ក្នុងការអភិវឌ្ឍ បច្ចុប្បន្ន ខេត្ត ស្វាយរៀង មានទំនប់ស្ទាក់ទឹកធំៗចំនួន ០២កន្លែង គឺនៅចំណុចស្ពានដូនស ក្នុងស្រុកស្វាយជ្រំ និងនៅស្ពានតាហោ ស្ថិតនៅក្នុងក្រុងស្វាយរៀង និងទំនប់ការពារទឹកជំនន់ (ទំនប់តាណោង) ព្រមទាំងច្រាំងទន្លេវៃគោ ដែលធ្វើឱ្យទន្លេវៃគោនេះអាចស្តុកទឹកបានប្រមាណ ៣០លាន ម៉ែត្រ គូប ជួយសម្រួលដល់ការប្រើប្រាស់ទឹក និងស្រោចស្រពដំណាំកសិកម្ម របស់បងប្អូនប្រជា កសិករ បានមួយចំនួនធំ និងជាកន្លែងបង្កើតពូជត្រីផងដែរ ហើយជាពិសេស សម្រាប់ជាកន្លែង រៀបចំការប្រណាំងទូកប្រពៃណីខ្នាតអន្តរជាតិ ដែលកាលពីសម័យមុន ខេត្តស្វាយរៀង ពុំដែ លមានការប្រណាំងទូកនេះទេ ទើបតែសម័យ **សម្តេចតេជោ** ក្រោមដំបូលកត្តាសុខសន្តិ ភាព ដែលខេត្តស្វាយរៀង មានលទ្ធភាពរៀបចំការប្រណាំងទូកនេះ ដើម្បីបង្កភាពសប្បាយ រីករាយជូនប្រជាពលរដ្ឋ ។

សូមជម្រាបជូនថា ការប្រណាំងទូកប្រពៃណីខ្នាតអន្តរជាតិនៅទន្លេវៃគោនេះ គឺក្រោម គំនិតផ្តួចផ្តើមឡើងដោយ **ឯកឧត្តមនាយឧត្តមសេនីយ៍ ហុក ឡុងឌី អតីតអគ្គស្នងការ នគរបាលជាតិ** តាំងពីឆ្នាំ២០០៨មក ដោយមានការគាំទ្រពីសំណាក់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច** និងជាប្រធានក្រុមការងារគណបក្ស ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តស្វាយរៀង **ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពល

ខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **ឯកឧត្តម ឌី វិជ្ជា អគ្គស្នងការរង នគរបាលជាតិ និងលោកជំទាវ ហ៊ុន ម៉ាណា** ព្រមទាំង ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ក្រុមការងារចុះជួយខេត្តស្វាយរៀង ជាច្រើនទៀត។

បន្ទាប់ពីការស្តាបនាប្រាំងទន្លេវៃគោនេះរួច **រដ្ឋបាលខេត្ត បាន**បន្តធ្វើការរៀបចំសួនច្បារ ដោយក្រាលការ៉ូឡា ដាក់បង្គោលភ្លើង ដាំស្មៅ ផ្កាលម្អ ឱ្យមានសោភ័ណភាព ដើម្បីជាកន្លែង ហាត់ប្រាណ និងលំហែកម្សាន្ត របស់បងប្អូនប្រជាពលរដ្ឋ និងទាក់ទាញភ្ញៀវទេសចរផងដែរ ។

ទន្ទឹមនេះ ខេត្តស្វាយរៀង សម្រេចបញ្ចប់នូវការអនុវត្តផែនការ ចំនួន ២ ជាចម្បង គឺ ជាខេត្តទីមួយ ដែលបានប្រកាស ជាខេត្តដែលបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល និងជា ខេត្តទី៨ ដែលបានប្រកាសជាខេត្ត អស់មីន ។

## ៣.អំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ផ្អែកលើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាល បានរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ រយៈពេល ១០ឆ្នាំ (២០១០-២០២០) ក្រោមការដឹកនាំរបស់ **សម្តេច ក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ កម្មវិធីជាតិនេះ ជាផែនទី បង្ហាញផ្លូវសម្រាប់ការអនុវត្តច្បាប់រៀបចំអង្គការ ជាជំហានៗ សំដៅឆានាដល់ការឯកភាព ស្រុះស្រួលគ្នា និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ សំដៅលើកកម្ពស់ការទទួលខុសត្រូវ និង ភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍសេដ្ឋកិច្ច ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

តាមរយៈកម្មវិធីកំណែទម្រង់នេះ ខេត្តស្វាយរៀង បានរៀបចំ និងដាក់ឱ្យដំណើរការនូវ អង្គភាពច្រកចេញចូលតែមួយខេត្ត ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងឃុំ សង្កាត់ ដែលជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព ទន្ទឹមនេះ ក៏ មានការិយាល័យប្រជាពលរដ្ឋ ដែលជាយន្តការអព្យាក្រឹត្យមួយ សម្រាប់ទទួល និងសម្រុះ សម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការ គ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ។

ជាក់ស្តែងនៅអង្គភាពច្រកចេញចូលតែមួយខេត្ត បានដំណើរការចាប់តាំងពី ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ មានរយៈពេលជាងប្រាំឆ្នាំ បានផ្តល់សេវារដ្ឋបាល សរុប ចំនួន ២០៦.០២៣សេវា ប្រាក់ចំណូលទទួលបានសរុបចំនួន ១៤.៣៥៦.០៩៥.២៧៦រៀល ។ សូមជម្រាបជូនផងដែរថា សេវារដ្ឋបាល ដែលត្រូវបានផ្តល់តាមរយៈអង្គភាពច្រកចេញចូលតែ

មួយខេត្ត មាន ១៤វិស័យ ស្មើនឹង ១៤៤ប្រភេទ និងមាន ៥២៧សេវា ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ និងសាធារណជនតាមច្បាប់កំណត់ ។

ចំពោះរដ្ឋបាលក្រុង ស្រុក ដែលមានការិយាល័យច្រកចេញចូលតែមួយ មានការផ្តល់សេវារដ្ឋបាល ចំនួន ១៨វិស័យ ស្មើនឹង ៥៥មុខងារ មាន ១៦២មុខងាររង និងមាន ២៧៨ សកម្មភាព ។

ចំពោះរដ្ឋបាលឃុំ សង្កាត់ ដែលមានការិយាល័យច្រកចេញចូលតែមួយ មានការផ្តល់សេវារដ្ឋបាល ចំនួន ១២ប្រភេទសេវា ។

ជាពិសេសនោះ នាចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ អនុក្រឹត្យលេខ ១៨២,១៨៣ និង ១៨៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ខណ្ឌ ស្រុក ដែលមានគោលបំណង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដោយកំណត់អំពីមុខងាររចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដែលនេះជាកំណែទម្រង់មួយដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងជាប្រវត្តិសាស្ត្រដែលធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ជារដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈក្នុង ដែនដីរបស់ខ្លួន ។

ដោយអនុវត្តតាមស្មារតីនៃអនុក្រឹត្យខាងលើ របស់រាជរដ្ឋាភិបាល និងដោយមានការដឹកនាំចង្អុលបង្ហាញពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** រដ្ឋបាលខេត្តស្វាយរៀង ក្រោមការដឹកនាំរបស់ **ឯកឧត្តមអភិបាលខេត្ត** បានយកចិត្តទុកដាក់រៀបចំធ្វើសមាហរណកម្មបុគ្គលិក ដែលកំពុងបម្រើការងារនៅតាមការិយាល័យអង្គភាព នៃរដ្ឋបាលក្រុង ស្រុក និងនៅតាមការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ចូលទៅក្នុងរចនាសម្ព័ន្ធថ្មី នៃរដ្ឋបាលក្រុង ស្រុក ធ្វើឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗមានចំនួនការិយាល័យ កើនពី ៥ការិយាល័យ ទៅ ១៣ការិយាល័យ ជាពិសេសចំនួនបុគ្គលិកមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដែលនៅមុនពេលធ្វើសមាហរណកម្ម សាលាក្រុង ស្រុកនីមួយៗ មានមន្ត្រី បុគ្គលិក គិតជាធម្យមប្រមាណជាង ២០នាក់ ប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ន សាលាក្រុង ស្រុកនីមួយៗ មានបុគ្គលិកបម្រើការងារគិតជាមធ្យម ៥៥នាក់ ។

## ៤. វិស័យអប់រំសិក្សាធិការ

ផ្អែកតាមគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការជំរុញលើកកម្ពស់វិស័យ អប់រំ ទាំងបរិមាណ និងគុណភាព ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឱ្យមានការីកចម្រើនប្រកបដោយចីរភាព បរិយាប័ន្ន ដោយបានកំណត់ថា ត្រូវពង្រីកអនុវិទ្យាល័យ ឱ្យបានគ្រប់ឃុំ សង្កាត់ និងមានវិទ្យាល័យ ០១កន្លែង យ៉ាងតិចនៅតាមបណ្តាក្រុង ស្រុក និងមានសាលាបឋមសិក្សានៅគ្រប់ភូមិទាំងអស់ ដែលជាក់ស្តែងគិតមកដល់ពេលនេះ នៅទូទាំងខេត្ត មានអគារសិក្សា ៩៦២ខ្នង ស្មើនឹង ៤.១៥៨បន្ទប់ មានសាលារៀនគ្រប់កម្រិតសិក្សា រួមមាន សាលាមត្តេយ្យរដ្ឋ ១៧៥សាលា ក្នុងនោះសាលាមត្តេយ្យដាច់ដោយឡែកមានចំនួន ០៦សាលា មត្តេយ្យសហគមន៍ ៣០៤កន្លែង សាលាបឋមសិក្សា ២៦២សាលា អនុវិទ្យាល័យ ៥៣សាលា វិទ្យាល័យ ២១សាលា សាលាគរុកោសល្យនិងវិក្រឹតការ ០១កន្លែង និងមានសាកលវិទ្យាល័យ ០១កន្លែង គឺសាកលវិទ្យាល័យស្វាយរៀង ដែលបានផ្តួចផ្តើមដឹកនាំកសាងដោយ **ឯកឧត្តមនាយឧត្តមនីយ៍ ហុក ឡុងឌី** អតីតអគ្គស្នងការនគរបាលជាតិ និងលោកជំទាវ **ឯកឧត្តម ហ៊ុន ណេង** អតីតអភិបាលខេត្តស្វាយរៀង **ឯកឧត្តម ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ រួមនឹងឯកឧត្តម លោកជំទាវ លោក លោកស្រីថ្នាក់ដឹកនាំ ក្រុមការងារគ្រប់លំដាប់ថ្នាក់ បានរួមគ្នាកសាងឡើងនៅអំឡុងឆ្នាំ២០០៤ ហើយត្រូវបានសម្ពោធដាក់ឱ្យដំណើរការកាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី** ហ៊ុនសែន ។

គិតមកដល់បច្ចុប្បន្ន សាកលវិទ្យាល័យស្វាយរៀង មាន ០៥ មហាវិទ្យាល័យ មាន ៣ កម្រិតគឺបរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ និងបរិញ្ញាបត្ររង មាននិស្សិតសិក្សាក្នុងមួយឆ្នាំៗ ប្រមាណ ៤.០០០នាក់ និងមាននិស្សិតបញ្ចប់ការសិក្សាប្រមាណជាង ៦.០០០នាក់ ដោយបានរៀបចំពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត ចំនួន ០៥លើក ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៣លើក។

ចំពោះអគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លា **របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ផ្តល់ជូនខេត្តស្វាយរៀង សរុបមានចំនួន ២០២ខ្នង ស្មើនឹង ១.២១០បន្ទប់ ជាពិសេសក្នុងរយៈពេលចុងក្រោយនេះ ក្នុងឱកាសដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញចុះសួរសុខទុក្ខបងប្អូនមន្ត្រីរាជការ និងកម្មករនិយោជិត **សម្តេច** បានផ្តល់អគារសិក្សាថ្មីៗចំនួន ២០ខ្នង ស្មើនឹង ២៣៦បន្ទប់ ដែលមានលក្ខណៈទំនើប និងល្អប្រណីត ហើយមានកម្ពស់រហូតដល់ទៅ ៤ជាន់ ។

សូមជម្រាបជូនផងដែរ នៅក្នុងខេត្តស្វាយរៀង មានវិទ្យាស្ថាន **ពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង** ដែលជាថ្នាលអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ជូនដល់សិស្ស និស្សិតចាប់ពីឆ្នាំ២០១៨-២០២២ មានចំនួន ១.៦៨៦នាក់ ស្រី ៤២៣នាក់ សិស្ស និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២៣នេះ មានចំនួន ១.១០៦នាក់ ស្រី ២៩១នាក់ ។ ចំពោះជំនាញដែលបានបណ្តុះបណ្តាលរួមមាន ជំនាញអគ្គិសនី ម៉ាស៊ីនត្រជាក់ យន្តសាស្ត្រ កុំព្យូទ័រ ទូរស័ព្ទ ធនាគារហិរញ្ញវត្ថុ ភាសាអង់គ្លេស រដ្ឋបាល គណនេយ្យ កាត់ដេរ អ៊ុតសក់ សំអាងការ ជួសជុលម៉ូតូ គ្រឿងម៉ាស៊ីនតូចធំ ចិញ្ចឹមសត្វ ដាំបន្លែចម្រុះ ដល់សិស្ស និស្សិត ទទួលបានជំនាញពិតប្រាកដឆ្លើយតបទៅនឹងទីផ្សារការងារ និងដើម្បីបង្កើតមុខរបរ លើកកម្ពស់ជីវភាពគ្រួសារឱ្យប្រសើរឡើង ។

បច្ចុប្បន្នវិស័យអប់រំ មានមន្ត្រីរាជការ បុគ្គអប់រំ សរុប ៤.៨៥៨នាក់ ស្រី១.៧២៦នាក់ ក្នុងឆ្នាំសិក្សា ២០២១-២០២២ មានសិស្សសរុប ១២៧.៩០៧នាក់ ស្រី ៦៣.៩៩៥នាក់ ក្នុងនោះសិស្សមត្តេយ្យសិក្សា ចំនួន ១៤.៤២៧នាក់ (ស្រី ៧.៤៣៧នាក់) សិស្សបឋមសិក្សា ចំនួន ៧.៤៦៨១នាក់ (ស្រី ៣៥៨២៨នាក់) សិស្សមធ្យមសិក្សាបឋមភូមិ ២៦.៣០៦នាក់ (ស្រី ១៣.២៧២នាក់) សិស្សមធ្យមសិក្សាទុតិយភូមិចំនួន១២.៤៩៣ នាក់ (ស្រី ៦.៥៣៦នាក់) ។ ចំពោះសិស្សដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០២២ សរុបមានចំនួន ២.៨៨០នាក់ ស្មើនឹង ៧៥.០៩% (ស្រី ១.៦៣៤នាក់) ស្មើនឹង ៨០.៦១% នៃចំនួនបេក្ខជនបានប្រឡងសរុប ៣.៨៣៥នាក់ (ស្រី ២.០២៧នាក់) ក្នុងនោះនិទ្ទេស A ចំនួន ១៧នាក់ (ស្រី០៦នាក់) និទ្ទេស B ចំនួន ២០៦នាក់ (ស្រី ១៣៣នាក់) និទ្ទេស C ចំនួន៦២៧នាក់ (ស្រី ៣៧៩នាក់) និទ្ទេស D ចំនួន ១.០២៤នាក់ (ស្រី ៥៩៥នាក់) និងនិទ្ទេស E ចំនួន ១.០០៦នាក់ (ស្រី ៥២១នាក់) ។

## ៥. ការងារវិស័យកសិកម្ម

វិស័យកសិកម្ម ដែលជាវិស័យមួយដ៏សំខាន់ក្នុងចំណោមវិស័យអាទិភាពនានានៅ ក្នុងខេត្តស្វាយរៀង ដែលបច្ចុប្បន្ន មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ។ នៅទូទាំងខេត្ត មានផ្ទៃដីផលិតកម្មកសិកម្ម សរុប ២០៥.៤៧៦ហិកតា ក្នុងនោះផ្ទៃដីផលិតកម្មដំណាំស្រូវ ១៨៨.០០០ហិកតា (ស្រូវវស្សា ១៦៧.៥០០ហិកតា និង ស្រូវប្រាំង ២០.៥០០ហិកតា) និងដំណាំរួមផ្សំ និងកសិ-ឧស្សាហកម្ម សរុប ១៧.៤៧៦ហ.ត (ដំណាំគ្រប់ប្រភេទ ៤.៣២៧ហិកតា និងផ្ទៃដីដំណាំកៅស៊ូជាលក្ខណៈគ្រួសារមានចំនួន ២.៣០២ហិកតា ផ្ទៃដីដំណាំអំពៅស្ករ ៤.៧៥៩ហិកតា និងដំឡូងមី ៦.០៨៨ហិកតា) ។

ក្នុងរដូវវស្សាឆ្នាំ២០២២ កន្លងទៅនេះ សម្រេចបានលើការដាំដុះ និងប្រមូលផលលើផ្ទៃដីសរុប ១៦៥.៩២៤ហ.ត ស្មើនឹង ៩៩,០៦% នៃផែនការ ១៦៧.៥០០ហ.ត ទិន្នផលជា

មធ្យម ២,៩តោន/ហ.ត និងបានដាំដំណាំរួមផ្សំ និងកសិឧស្សាហកម្ម លើផ្ទៃដីសរុប ៩.១៣៦ ហ.ត ស្មើនឹង ៤៤,៣៥% នៃផែនការសរុប ២០.៦០០ហ.ត ។

ដោយមានការរីកចម្រើនផ្នែកបច្ចេកទេស និងបច្ចេកវិទ្យា បានធ្វើឱ្យបងប្អូនប្រជាពលរដ្ឋផ្លាស់ប្តូរការងារបង្កបង្កើនផលពីតាមបែបប្រពៃណី មកតាមបែបទំនើបកម្មកសិកម្មវិញ ដោយប្រើប្រាស់គ្រឿងយន្តកសិកម្មជំនួសកម្លាំងពលកម្មមនុស្ស និងកម្លាំងអូសទាញដោយ គោក្របី ប្រមាណ ៩៦% ដែលក្នុងនោះ នៅទូទាំងខេត្ត មានគ្រឿងយន្តកសិកម្ម សរុប ៥២.៦៨៣គ្រឿង (ត្រាក់ទ័រ ១.៨៣៤គ្រឿង គោយន្ត ២.៦៧៩គ្រឿង ម៉ាស៊ីនច្រូតស្រូវ ៣៦៥គ្រឿង ម៉ាស៊ីនបូមទឹក ៣៩.៤៧៩គ្រឿង ម៉ាស៊ីនស្ទូង ៧គ្រឿង ម៉ាស៊ីនបោកស្រូវ ១៩គ្រឿង) ។

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ខេត្តស្វាយរៀង ផលិតស្រូវបានចំនួន ២.៨៣៩.៩២៩-តោន ក្នុងនោះបាននាំចេញទៅលក់នៅប្រទេសជិតខាងចំនួន ១.០៤២.៦០៥តោន ហើយអតិរេកស្រូវដែលនៅសល់បម្រុងទុកជាស្បៀងអាហារចំនួន ១.៧៩៧.៣២៤តោន ។

ដោយឡែកតុល្យភាពស្បៀងនៅក្នុងឆ្នាំ២០២២ ខេត្តមានអតិរេកគិតជាស្រូវ មានចំនួន ៥៦១.៣៨៣តោន ស្មើនឹងអង្ករ សរុប ចំនួន ៣១២.៥៧៨តោន ។ ក្រៅពីផលិតកម្មដំណាំស្រូវ ខេត្តស្វាយរៀង ក៏មានសក្តានុពលលើដំណាំកសិ-ឧស្សាហកម្ម រួមមាន ដំណាំអំពៅស្ករ ដំឡូងមី សម្រាប់ផលិតជាវត្ថុធាតុដើមលក់ចេញទៅកាន់ទីផ្សារនៃប្រទេសជិតខាង និងដំណាំសម្រាប់ផ្គត់ផ្គង់តម្រូវការនៅនឹងកន្លែង និងនាំចេញទៅកាន់ទីផ្សារក្នុងស្រុក ដែលក្នុងឆ្នាំ ២០២២ ផលិតផលក្នុងខេត្ត បាននាំចេញទៅកាន់ទីផ្សារក្នុងស្រុក និងប្រទេសជិតខាងរួមមាន ស្រូវមានបរិមាណ **៤១៦.៥០៧តោន** អំពៅស្ករ (ស្រស់) ជាង **៤១០.៣៨៧តោន** ដំឡូងមី ២៣.៦០៧តោន ។ ជាមួយនេះនៅមានបន្លែសុវត្ថិភាពដែលបានដាំដុះលើផ្ទៃដី ប្រមាណជា ២១០ហិកតា ដោយប្រជាកសិករ ចំនួន ៥១១គ្រួសារ នៅតាមបណ្តាក្រុង ស្រុក ក៏បានក្លាយជាផលិតផល សម្រាប់នាំចេញទៅកាន់ទីផ្សារក្នុងស្រុក ជាពិសេសនៅតាមផ្សារទំនើប នៅរាជធានីភ្នំពេញ បានប្រមាណជាង ២៥០តោន ក្នុងមួយឆ្នាំ។ ក្រៅពីនេះយើងបានជំរុញការចិញ្ចឹមសត្វ ចិញ្ចឹមត្រី ទាំងនៅតាមសហគមន៍ និងនៅតាមស្រះរបស់ប្រជាពលរដ្ឋ ឱ្យមានសកម្មភាពយ៉ាងផុលផុសផងដែរ ដែលបច្ចុប្បន្ននៅក្នុងខេត្ត មានស្រះចិញ្ចឹមត្រី ចំនួន ៤៥០កន្លែង មានកសិដ្ឋានចិញ្ចឹមជ្រូកខ្នាតតូច ២៤៣កន្លែង ខ្នាតមធ្យម ២១កន្លែង និងកសិដ្ឋានខ្នាតធំចំនួន ១ កន្លែង ដែលមានជ្រូកប្រមាណ ៨៤.០០០ក្បាល ព្រមទាំងមានសហគមន៍ព្រៃឈើចិញ្ចឹមឃ្មុំ ០១ កន្លែង ផ្ទៃដី ប្រមាណ ៤០០ហិកតា ផងដែរ នៅស្រុករមាសហែក ។

-នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជា

ណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានចែកពូជស្រូវជូនកសិករដែលរងគ្រោះដោយសារជំនន់ទឹកភ្លៀង ចំនួន ១០២០គ្រួសារ ក្នុង១គ្រួសារ ទទួលបាន ពូជស្រូវចំនួន ១០០គីឡូក្រាម មី ១កេស និងថវិកាចំនួន ៥០.០០០រៀល ។

-ចាប់ពីថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០២០ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បានចុះចែកពូជដំណាំជូនដល់កសិកររងគ្រោះនៅតាមបណ្ដាក្រុង ស្រុក សរុបចំនួន ៥៥២គ្រួសារ នៅក្នុង១គ្រួសារទទួលបានគ្រាប់ពូជដំណាំចំនួន ១ឃីត (ក្នុង១ឃីត មានគ្រាប់ពូជបន្លែ ០៤មុខ គឺ ស្ពៃខៀវ ត្រប់វែង ពោតដំណើប និងសណ្ដែកកួរ) ។

-នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតី ចែកស្រូវពូជ ជូនគ្រួសារប្រជាពលរដ្ឋដែលរងគ្រោះ ដោយជំនន់ទឹកភ្លៀង ចំនួន ២៧៣គ្រួសារ ក្នុង១គ្រួសារទទួលបានស្រូវពូជ ចំនួន ១០០ គ.ក អង្ករ ៥០គ.ក មី ១កេស ត្រីខកំប៉ុង ០៦កំប៉ុង ទឹកស៊ីអ៊ីវ ០៦ដប និងថវិកា ៥០.០០០៛ ។

## ៦. ការងារធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

ខេត្តស្វាយរៀងមានប្រភពសក្ដានុពលធនធានទឹក បម្រើឱ្យការប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្មមាន ០៣ ធំៗ គឺ ទន្លេកំពង់ត្រាច ស្ថិតនៅស្រុករមាសហែក ទន្លេវៃគោ ស្ថិតនៅក្រុងស្វាយរៀង និងព្រែកព្រំដែនកម្ពុជា-វៀតណាម ។ ក្រៅពីនេះក៏មានព្រែកចំនួន ១១ព្រែក និងមានអូរចំនួន ៣៩អូរ និងកំពុងបន្តស្តារ សាងសង់បន្ថែមទៀត ។

**ក.ប្រព័ន្ធធារាសាស្ត្រនៅទូទាំងខេត្ត សរុប ចំនួន ៣៥ ប្រព័ន្ធ ៖**

-ប្រព័ន្ធធារាសាស្ត្រតូចមាន ចំនួន ០២ប្រព័ន្ធ ប្រព័ន្ធធារាសាស្ត្រធំមាន ចំនួន ០៦ប្រព័ន្ធ និងប្រព័ន្ធធារាសាស្ត្រមធ្យមមានចំនួន ២៧ ប្រព័ន្ធ ។

-ទំនប់អាងទឹកមានចំនួន ១៥ កន្លែង និងកំពុងមានផែនការសាងសង់ ចំនួន ០៤ កន្លែង បន្ថែមទៀត ស្មើនឹង ១៩ កន្លែង ។

-ប្រឡាយមេមាន ២៨ ខ្សែ ប្រវែងសរុប ៥២០.២០០ ម៉ែត្រ

-ប្រឡាយរងទី១មាន២៧ខ្សែ ប្រវែងសរុប ១០៣.៧៧៥ ម៉ែត្រ

-ស្ថានីយបូមទឹកធំៗសរុបមានចំនួន ០៤កន្លែង

-ប្រឡាយជើងក្អែបមានប្រវែងសរុប ៧២៨.០២៦ ម៉ែត្រ ។

**ខ.លទ្ធភាពស្រោចស្រព ៖**

គិតត្រឹមឆ្នាំ២០២២ ប្រព័ន្ធធារាសាស្ត្រសរុបទាំងអស់ចំនួន ៣៥ ប្រព័ន្ធអាចមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រូវប្រាំង ២១.២០៦ហ.ត និងស្រូវវស្សា ចំនួន ៦៧.៥៧៩ហ.ត សរុប

ចំនួន ៨៨.៧៨៥ ស្មើនឹង ៤៧,២៣% បើប្រៀបធៀបផែនការស្រូវប្រាំងចំនួន ២០.៥០០ហ.ត និង ស្រូវវស្សាចំនួន ១៦៧.៥០០ហ.ត សរុបមានចំនួន ១៨៨.០០០ហ.ត ។ ប្រៀបធៀបឆ្នាំ២០១៨ មានលទ្ធភាពស្រោចស្រព ចំនួន ៦៥.៧២៩ ស្មើនឹង ៣៥ ,១៥ % ខុសគ្នាចំនួន ១២,០៨ % ។

**គ.ការងារស្តារ ជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រ នៅតាមស្រុក ក្រុង ៖**

-ការស្តារ ជួសជុល និងសាងសង់គម្រោងអភិវឌ្ឍន៍ ប្រព័ន្ធប្រឡាយកីចកចាប់ផ្តើមសាងសង់ឆ្នាំ ២០១១ - ២០២០ ( ១០ ជំហាន) ៖ ប្រព័ន្ធធារាសាស្ត្រនេះបម្រើអោយការស្រោចស្រព លើផ្ទៃដីចំនួន ៥០.០០០ហ.ត ក្នុងនោះ ស្រូវរដូវប្រាំងចំនួន ២០.០០០ហ.ត មានប្រជាពលរដ្ឋ ទទួលផល ០៦ក្រុង ស្រុក ។ ប្រព័ន្ធធារាសាស្ត្រនេះក្រៅពីបម្រើការស្រោចស្រពដាំណាំស្រូវ មាន តួនាទីសំខាន់មួយទៀត គឺនាំទឹកពីទន្លេមេគង្គនារដូវទឹកឡើងនៅរដូវវស្សាទៅបំពេញអាងទឹកចំនួន ០៤ទៀត ។

-ស្តារប្រឡាយមេ ០៣ខ្សែបានប្រវែង ៧៥.៨០០ម៉ែត្រ

-ស្តារប្រឡាយរង ១៥ខ្សែបានប្រវែង ៣៨.៣៦០ម៉ែត្រ

-សំណង់សិល្បៈការតូចធំចំនួន ៣៩០កន្លែង

-ស្ពានឆ្លងកាត់ផ្លូវ ០២កន្លែង

-សំណង់បង្ហៀរទឹក ០២ កន្លែង

-សាងសង់ទំនប់សណ្តរប្រវែង ៨០០ ម៉ែត្រ

-សាងសង់ស្ថានីយបូមទឹក ០១ កន្លែង

-សាងសង់សំណង់អគារសហគមន៍កសិករប្រើប្រាស់ទឹក ០១ ខ្នង

-ការស្តារ ជួសជុល និងសាងសង់គម្រោងអភិវឌ្ឍន៍ ប្រព័ន្ធធារាសាស្ត្រ វ៉ៃគោជំហ៊ាន២ ឆ្នាំ ២០១៧-២០២២ រួមមានដូចខាងក្រោមនេះ ៖

-សាងសង់សំណង់សិល្បៈការខ្នាតតូចប្រើប្រាស់សាច់ប្រាក់ពលកម្មមានចំនួន ៤៨កន្លែង និងសាងសង់សំណង់លូស្រោចស្រព និងដោះទឹក ជាច្រើនកន្លែង ស្ថិតនៅស្រុកស្វាយជ្រំ ។

-ជួសជុលទំនប់មេ បានប្រវែង ១.២០០ ម៉ែត្រ ស្ថិតនៅស្រុកស្វាយជ្រំ

-សាងសង់ទំនប់សណ្តរមានប្រវែង ២២.៤០០ម៉ែត្រ ស្ថិតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

-ការងារអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ បានកំពុងដំណើរការជួសជុល ស្តារ សាងសង់ ប្រឡាយជើងក្អែប និងសាងសង់សំណង់សិល្បការដោយប្រើប្រាស់សាច់ប្រាក់ពលកម្មចាប់ពីឆ្នាំ

២០១៨ រហូតដល់ឆ្នាំ២០២២ ដោយសម្រេចលទ្ធផលបានប្រវែង ៤៥៤.៧៦៨ម៉ែត្រ និងសាងសង់សំណង់សិល្បៈការខ្នាត តូចបានចំនួន ១១៨កន្លែង ។

### ៧. វិស័យសុខាភិបាល

វិស័យសុខាភិបាល ជាវិស័យអទិភាពមួយដ៏សំខាន់ក្នុងការផ្តល់សេវាសុខភាពសាធារណៈ ជូនប្រជាពលរដ្ឋ ដែលជាបុព្វហេតុរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចិរភាព ។ ជាក់ស្តែងនៅក្នុងទូទាំងខេត្ត មានមន្ទីរពេទ្យខេត្ត ០១កន្លែង មន្ទីរពេទ្យបង្អែកចំនួន ០៥កន្លែង និងមានការិយាល័យស្រុកប្រតិបត្តិ (OD) ចំនួន ០៤កន្លែង មានមណ្ឌលសុខភាព ចំនួន ៤៨កន្លែង ព្រមទាំងមានប៉ុស្តិ៍សុខភាពចំនួន ០២កន្លែង មានមន្ត្រីសុខាភិបាលសរុប ៩៣២នាក់ ( ស្ត្រី ៤៨១នាក់ )។

- រយៈពេល ៥ឆ្នាំចុងក្រោយនេះ មន្ទីរសុខាភិបាលខេត្តទទួលបានៈ
  - បុគ្គលិកក្របខ័ណ្ឌរដ្ឋចូលបម្រើការងារសរុបចំនួន ៣៣៨ នាក់
  - ពិនិត្យព្យាបាលជំងឺក្រៅសរុបចំនួនៈ ១.៥៤៥.៣០៥ ករណី
  - ព្យាបាលជំងឺសំរាកពេទ្យសរុបចំនួនៈ ១៥៦.៨៧០ ករណី
  - សាងសង់បានអគារមន្ទីរពេទ្យបង្អែកចំនួន ០១ អគារ
  - សាងសង់បានអគារមណ្ឌលសុខភាពថ្មីចំនួន ០៥ អគារ
  - ទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ សរុបចំនួនៈ ៧.២៨៧នាក់ ( ស្ត្រី ៣.៩៩៤នាក់ )
- បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋបានៈ
  - ដូសមូលដ្ឋាន ចំនួន ៤៨៣.៨៦៧ នាក់ ស្មើនឹង ១០២%
  - ដូសជំរុញចំនួន ៣៧៩.៤៨៨ នាក់ ស្មើនឹង ៨០%
- **អំពីវិធានការ បង្ការការពារ ទប់ស្កាត់ ការឆ្លងជំងឺកូវីដ-១៩**

ដោយអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំប្រកប ដោយគតិបណ្ឌិត និងការណែនាំរបស់ក្រសួងមហាផ្ទៃ ព្រមទាំងក្រសួងសុខាភិបាល រដ្ឋបាលខេត្តស្វាយរៀង បានបង្កើតគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលមាន **ឯកឧត្តមអភិបាលខេត្ត** ជាប្រធាន ជាពិសេស មានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង ដែលដឹកនាំដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** បានផ្តល់នូវការណែនាំបន្ថែមជាក់ស្តែងដល់អាជ្ញាធររដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ព្រមទាំងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ក្រុង ស្រុក ឃុំ សង្កាត់ ទាំងអស់ ឱ្យយកចិត្តទុកដាក់ ចាត់វិធានការ អនុវត្តចុះធ្វើការអប់រំ ណែនាំ ដល់បងប្អូនប្រជាពលរដ្ឋ នៅគ្រប់សហគមន៍មូលដ្ឋាន ភូមិ ឃុំ សង្កាត់ទាំងអស់

ឱ្យមានការយល់ដឹងអំពីការធ្វើអនាម័យផ្ទាល់ខ្លួន នៅតាមគ្រួសារនីមួយៗ ជាពិសេសការយល់ដឹងអំពីវិធានការបង្ការ ទប់ស្កាត់ ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលជាជំងឺឆ្លងដ៏កាចសាហាវ ដែលបានកើតមាន និងរីករាលដាលជាសកល នៅទូទាំងពិភពលោក ក៏ដូចជានៅក្នុងប្រទេសកម្ពុជាយើង ដែលកិច្ចការនេះ យើងត្រូវចូលរួមទាំងអស់គ្នា ដោយផ្តើមពីមនុស្សម្នាក់ គ្រួសារនីមួយៗ សហគមន៍នីមួយៗ ដើម្បីការពារកុំឱ្យមានការឆ្លងមេរោគកូវីដ-១៩ នៅក្នុងគ្រួសារ និងនៅតាមសហគមន៍របស់យើង ដោយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងត្រឹមត្រូវ តាមការណែនាំរបស់រាជរដ្ឋាភិបាល និងវិធានការរបស់ក្រសួងសុខាភិបាល តាមគ្រប់រូបភាព និងមធ្យោបាយ ដែលអាចធ្វើទៅបាន ដោយប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប វិធានការសរុប ដោយក្នុងនោះ ក៏បាននាំយកទៅជាមួយនូវសម្ភារ មួយចំនួន ដូចជា ម៉ាស់ ទឹកអាល់កុល សាប៊ូលាងដៃ ក្រម៉ា អង្ករ ព្រមទាំងគ្រឿងឧបភោគបរិភោគផ្សេងៗទៀត ដើម្បីចែកជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត ក្នុងការចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ឱ្យទទួលបានជោគជ័យ ដើម្បីធានាសុខុមាលភាពប្រជាពលរដ្ឋឱ្យបានល្អ ។ ជាក់ស្តែងខេត្ត បានរៀបចំទីកន្លែងសម្រាប់ព្យាបាលជំងឺកូវីដ-១៩ មាននៅមន្ទីរពេទ្យបង្អែកខេត្ត ក្រុង ស្រុក ចំនួន ៧ ទីតាំង កាស៊ីណូបាវិតម៉ុកបៃ សណ្ឋាគារវ៉េគោ ផ្ទះសំណាក់ស្វាយរៀង និងផ្ទះសំណាក់គ្រូបង្រៀន សរុបមាន ១.៣៥៨បន្ទប់ ស្មើនឹង ២.៥៨២គ្រែ ។

អនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់ របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត ដែលមាន **ឯកឧត្តម ម៉ែន វិបុល អភិបាល នៃគណៈអភិបាលខេត្ត** និងជាប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានយកចិត្តទុកដាក់ ក្នុងការជួយសម្របសម្រួល បង្ករលក្ខណៈងាយស្រួលដល់បងប្អូនពលករទាំងអស់ ដែលវិលត្រលប់មកមាតុប្រទេសស្រុកកំណើតវិញ ដោយបានបង្កើតក្រុមការងារមួយក្រុមដឹកនាំដោយ**អភិបាលរងខេត្ត** ០១រូប ដើម្បីធ្វើការទំនាក់ទំនង និងសហការជាមួយអាជ្ញាធរខេត្តជាប់ព្រំដែន ជាមួយប្រទេសថៃ ដើម្បីសម្របសម្រួលដោះស្រាយដល់ការធ្វើដំណើររបស់បងប្អូនពលករ ពីព្រំដែនមកកាន់លំនៅឋានរបស់ពួកគាត់ ក៏ដូចជាការជួយឧបត្ថម្ភម្ហូបអាហារ ទឹក សម្ភារ ថ្នាំពេទ្យ និងផ្តល់ការអប់រំណែនាំ អំពីវិធានការ អនាម័យ ថែរក្សាសុខភាព វិធានការចត្តាឡីស័ក ឱ្យពួកគាត់ដាក់ខ្លួននៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ព្រមទាំងវិធានការផ្សេងៗទៀត តាមការណែនាំរបស់ក្រសួងសុខាភិបាល ហើយបងប្អូនពលករ ក៏ដូចជាបងប្អូន ប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋាន សហគមន៍ក្នុងខេត្តស្វាយរៀងទាំងមូល យកចិត្តទុកដាក់ចូលរួមអនុវត្តតាមការណែនាំ និងវិធានការទាំងឡាយ របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសវិធានការណែនាំ អប់រំ របស់ក្រសួងសុខាភិបាល ក្នុងការបង្ការ ទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ-១៩នេះ ជាក់ស្តែង គិត

មកដល់ពេលនេះ ខេត្តស្វាយរៀង ពុំទាន់មានបងប្អូនពលករ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋណាម្នាក់ មានជំងឺកូវីដ-១៩ នៅឡើយទេ ។

## ៨. វិស័យសាធារណការ និងការដឹកជញ្ជូន

-ផ្លូវខេត្តសរុបមានចំនួន ៥៨ខ្សែ និងផ្លូវជាតិចំនួន ៣ខ្សែ ដែលក្នុងនោះសម្រេចបានការចាក់ផ្លូវកៅស៊ូ AC/DBST/SBST ប្រវែង ២១១.០២៣គីឡូម៉ែត្រ ផ្លូវបេតុងទំហំ ២.៧៣៤-ម៉ែត្រការ៉េ និងផ្លូវក្រួសក្រហមប្រវែង ៧៥.៤៥គីឡូម៉ែត្រ។

-ការងារដាក់លូ និងថែទាំលូបណ្តោយផ្លូវ លូជ្រុងមានចំនួន ១៧០.២១៧គីឡូម៉ែត្រ រីហ្គាមានចំនួន ២៨៩កន្លែង ការងារដាក់លូទទឹងផ្លូវមានចំនួន ៥៥កន្លែង ។

-ការងារថែទាំផ្លូវកៅស៊ូDBSTមានចំនួន ៦៨២,៣៦គីឡូម៉ែត្រ ការងារថែទាំក្រាលដីល្បាយថ្ម ៤៦៥,៩៧គីឡូម៉ែត្រ ។

-ក្រសួងសាធារណការ និងដឹកជញ្ជូន បានអនុវត្តការងារស្តាបនា ផ្លូវជាតិ ចំនួន ០២ខ្សែ គឺផ្លូវជាតិលេខ១៣ ពីក្រុងស្វាយរៀង រហូតដល់ផ្លូវជាតិលេខ៨ ខេត្តព្រៃវែង ប្រវែងសរុប ៥៩គីឡូម៉ែត្រ និងផ្លូវជាតិលេខ១៨ ពីទីប្រជុំជនប្រសូត្រ រហូតដល់ច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ប្រវែងសរុប ២៥,៦៦គីឡូម៉ែត្រ និងបានស្ថាបនាទីស្នាក់ការត្រួតពិនិត្យច្រកព្រំដែនអន្តរជាតិព្រៃវល្លិ៍ អនុវត្តដោយគម្រោងរបស់ ABD ។

-បានស្ថាបនាទីលានញែកសំរាម ស្ថិតនៅសង្កាត់បានទី មានទំហំ ៦៧ម x ៣៧ម អនុវត្តដោយគម្រោង ABD និងមានគម្រោងស្ថាបនាអាងចម្រោះទឹកកង្វក់ ០១កន្លែងស្ថិតនៅក្រុងបាវិត លើផ្ទៃដីប្រមាណជាង ២០ហិកតា ដែលនឹងត្រូវចាប់ផ្តើមការអនុវត្តការសាងសង់ក្នុងឆ្នាំ ២០២៣តទៅ។

-បានស្ថាបនាកំពង់ផែអូស្នាច់ និងផ្លូវទឹក ១ខ្សែប្រវែង ៦.៩៧០គីឡូម៉ែត្រ ចាប់កំពង់ផែអូស្នាច់ ក្រុងស្វាយរៀង ដល់ព្រំប្រទល់កម្ពុជា-វៀតណាម ដែលមានទទឹងមាត់លើ ៤០ម៉ែត្រ បាតក្រោម ២០ម៉ែត្រ និងជម្រៅ ៤ម៉ែត្រ ។

## ៩. វិស័យអភិវឌ្ឍន៍ជនបទ

-បានជួសជុលផ្លូវជនបទ ដោយក្រាលខ្សាច់ភ្នំ និងបេតុងចំនួន ៣កំណាត់ផ្លូវ និង ៦ខ្សែ ប្រវែង ២៤,៤៥គ.ម បានសាងសង់ផ្លូវជនបទ ក្រាលកៅស៊ូពីរជាន់ប្រភេទ(DBST)ចំនួន ១០ខ្សែប្រវែង ៩៨គ.ម បានថែទាំផ្លូវជនបទជាលក្ខណៈខួប ដោយក្រាលខ្សាច់ភ្នំ និងក្រួសក្រហម ចំនួន ១០ខ្សែ ប្រវែង ៩១,២២ គ.ម បានថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ ក្រាលខ្សាច់ភ្នំនិងក្រួសក្រហម ចំនួន ៤៧ខ្សែ ប្រវែង ៤៦៧,២៩គ.ម និងបានថែទាំផ្លូវជនបទជាលក្ខណៈប្រចាំកៅស៊ូពីរជាន់DBST ចំនួន ៨ខ្សែ ប្រវែង ១២៤,៤គ.ម ។

-បានថែទាំផ្លូវជនបទ ក្នុងគម្រោងជួសជុលបន្ទាន់ ដោយក្រាលខ្សាច់ក្រួស និងក្រួសក្រហម ចំនួន ១៩កំណាត់ ប្រវែង ២៦,៩គ.ម ។

-បានជួសជុល និងស្តារឡើងវិញផ្លូវដីស ចំនួន ៣៦៥អនុគម្រោង ប្រវែង ៣២៥,១៩៩គ.ម ក្នុងគម្រោងសាច់ប្រាក់ពលកម្ម និងក្រាលក្រួសក្រហម និងខ្សាច់ក្រួសលើផ្លូវដីស ប្រវែង ១៣៦គ.ម ។

-បានប្រារព្ធពិធីប្រកាសខេត្តទទួលស្គាល់ជាផ្លូវការខេត្តស្វាយរៀង ជាខេត្តទី១ បានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF)។

-បានចុះជំរុញការសាងសង់បង្គន់អនាម័យនៅតាមសហគមន៍ និងបានផ្តល់សម្ភារបង្គន់អនាម័យគ្រឿងក្រោមជូនប្រជាពលរដ្ឋក្រីក្រចំនួន ១.៦៣០គ្រឿង ។

-បានបណ្តុះបណ្តាលជំនាញរយៈពេលវែង (៤ខែ) ជូនប្រជាកសិករ យុវជន-នារី ចំនួន ៦៧វគ្គ សិក្ខាកាមសរុបចំនួន ១.១៨២នាក់ ស្រី៥៣០នាក់។

-បានផ្តល់ស្រះទឹកគ្រួសារចំនួន ១៤កន្លែង កូនឈើចម្រុះចំនួន ២.៦៩០ដើម ពូជមាន់ចំនួន ១២០ក្បាល និងកូនត្រី ចំនួន ៣.០០០ក្បាល ជូនដល់កសិករចំនួន ៣៥៤គ្រួសារ ។

## ១០. វិស័យការងារ និងវិនិយោគឯកជន

អនុវត្តតាមគោលនយោបាយបើកទូលាយ និងការលើកទឹកចិត្ត ដល់វិស័យវិនិយោគឯកជនរបស់រាជរដ្ឋាភិបាល ធ្វើឱ្យខេត្តស្វាយរៀង មានការអភិវឌ្ឍរីកចម្រើន គួរឱ្យកត់សម្គាល់ជាក់ស្តែងមកដល់បច្ចុប្បន្ននេះ ខេត្តស្វាយរៀង មានតំបន់សេដ្ឋកិច្ចពិសេស ចំនួន ១២កន្លែង និងកំពុងដំណើរការចំនួន ៩កន្លែង និងសហគ្រាសមួយចំនួនទៀតស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលមានរោងចក្រ សហគ្រាស សរុបមានចំនួន ២៦២កន្លែង បានបង្កើតការងារធ្វើជូនប្រជាពលរដ្ឋប្រមាណជាង **៩ម៉ឺននាក់** រួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ បងប្អូនកម្មករ កម្មការិនីទាំងអស់ ដែលកំពុងបម្រើការងារនៅតាមរោងចក្រ សហគ្រាស សុទ្ធតែទទួលបាននូវប្រព័ន្ធគាំពារសង្គមលើការថែទាំសុខភាព តាមរយៈការទទួលបាននូវប័ណ្ណបេឡាជាតិសន្តិសុខសង្គម (បសស) សម្រាប់ប្រើប្រាស់ក្នុងការថែទាំ និងព្យាបាលជំងឺដោយឥតគិតថ្លៃ ។

ផលរបរដែលបងប្អូនកម្មករ និយោជិតទទួលបានពីការបំពេញការងារនៅតាមរោងចក្រ សហគ្រាស មានប្រមាណ ២៣ ទៅ ២៥លានដុល្លារអាម៉េរិក ក្នុងមួយខែ ។

វិស័យផលិតកម្មសំខាន់ៗក្រៅពីសម្លៀកបំពាក់ រួមមាន ដំឡើងរថយន្ត ផលិតកង់ នាឡិកា សំបកកង់ឡាន ម៉ាស់ បរិក្ខាសុខាភិបាល អំពូលភ្លើង គ្រង់ស្នូរអគ្គិសនី ធ៍ត្រ គ្រឿង

សង្ក្រាវីម បារី តុក្កតា សាឡុង និងវត្ថុអនុស្សាវរីយ៍ផ្សេងៗ សម្រាប់គោលដៅនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ប្រទេសចិន និងប្រទេសផ្សេងៗទៀត ។

**ពិធីសំណេះសំណាលជាមួយកម្មករ និយោជិត**

-កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការរោចក្រដំឡើងរថយន្ត របស់ក្រុមហ៊ុន Deahan Auto នៅតំបន់សេដ្ឋកិច្ចពិសេស Intervior Automobile Industry Complex ក្រុងបាវិត ដោយបានអញ្ជើញសំណេះសំណាលជាមួយបងប្អូនកម្មករ និយោជិត ចំនួន ១៩.៤៨៩ នាក់ ។ ជាមួយគ្នានេះដែរ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងសម្តេចតេជោ នាយករដ្ឋមន្ត្រី បានរៀបចំពិធីសំណេះសំណាលជាមួយបងប្អូនកម្មករ និយោជិត នៅគ្រប់តំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្ត ។

-ឯកឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យដំណើការរោងចក្រ RMKH Glove (Cambodia) Co.Ltd នៅតំបន់សេដ្ឋកិច្ចពិសេសមែនហាតធេន ក្រុងបាវិត ដោយមានការចូលរួមពីបងប្អូនកម្មករ កម្មការិនី សរុបចំនួន ៩០០នាក់ ។ ទន្ទឹមនេះ ឯកឧត្តមបណ្ឌិត ក៏បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងមន្ត្រីរាជការ នៅក្រុងស្វាយរៀង ចំនួន ៧៩២នាក់ ។

ក្រៅពីនេះ មានថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ធុរជន វិនិយោគិនបរទេស ឯកអគ្គរដ្ឋទូតឯកអគ្គរាជទូតនានា បានធ្វើទស្សនកិច្ចសិក្សាឈ្វេងយល់ពីសង្វាក់ផលិតកម្មនៅតាមរោងចក្រនានា ក៏ដូចជាសិក្សាពីសក្តានុពលវិនិយោគនៅខេត្តស្វាយរៀងផងដែរ ។

**-ផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩**

ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ នៅខេត្តស្វាយរៀង មានរោងចក្រសហគ្រាស ព្យួរការងារ ចំនួន ៣២រោងចក្រ សហគ្រាស ស្មើនឹង ១១២លើក ក្នុងនោះ រោងចក្រ ក្នុងវិស័យកាត់ដេរ ដែលទទួលបានប្រាក់ឧបត្ថម្ភ ចំនួន ២២រោងចក្រ ស្មើនឹង ចំនួន ៩១លើក កម្មករ និយោជិតដែលទទួលបានប្រាក់ចំនួន ២៦.៣២៦នាក់ (ស្រី ២១.១៦៨នាក់) ស្មើនឹងទឹកប្រាក់ ចំនួន ១.១១៩.៧៥០ដុល្លារ និងរោងចក្រក្រៅវិស័យកាត់ដេរ មិនទទួលបានប្រាក់ឧបត្ថម្ភចំនួន ១០រោងចក្រ ស្មើនឹងចំនួន ២១លើក ។

## ១១. វិស័យបរិស្ថាន

រដ្ឋបាលខេត្ត ដោយមានមន្ទីរបរិស្ថាន ជាសេនាធិការ បានយកចិត្តទុកដាក់ លើកិច្ចគាំពារការងារបរិស្ថាន ការគ្រប់គ្រងសំណល់រឹង និងសំណល់រាវចេញពីបណ្តាប្រភពបំពុលទាំងអស់ក្នុងខេត្ត ។ កន្លងមកក្នុងកិច្ចគាំពារបរិស្ថាននេះ ជាពិសេសលើការគ្រប់គ្រងសំណល់ រឹង រាវតាមទីប្រជុំជន រដ្ឋបាលខេត្ត បានណែនាំដល់មន្ទីរបរិស្ថានខេត្ត ក៏ដូចជារដ្ឋបាលក្រុង ស្រុក ឱ្យធ្វើការអប់រំណែនាំផ្សព្វផ្សាយអំពីការទុកដាក់ និងវេចខ្ចប់កាកសំណល់ឱ្យបានត្រឹមត្រូវ មិនតែប៉ុណ្ណោះ រដ្ឋបាលខេត្ត បានណែនាំដល់អាជ្ញាធរក្រុង ស្រុក ឱ្យយកចិត្តទុកដាក់រៀបចំធុងសំរាមនៅតាមដងផ្លូវ សួនច្បារសាធារណៈ និងទីផ្សារ និងបានជំរុញឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាមយកទៅដាក់នៅទីលានចាក់សំរាម ដែលអាជ្ញាធរបានកំណត់ឱ្យបានត្រឹមត្រូវ ព្រមទាំងបំផុសស្មារតីប្រជាពលរដ្ឋក្នុងការចូលរួមលើកកម្ពស់ការយល់ដឹងពីអនាម័យ បរិស្ថាន ទាំងនៅក្នុងទីក្រុង និងទីប្រជុំជន ។ ជាមួយគ្នានោះ រដ្ឋបាលខេត្ត បានដាក់ចេញនូវវិធានការដល់មន្ទីរ ស្ថាប័នពាក់ព័ន្ធ ជាពិសេសមន្ទីរបរិស្ថានខេត្ត ក្នុងការចុះតាមដាន ត្រួតពិនិត្យជាប្រចាំនៅតាមបណ្តាប្រភពបំពុលនានាក្នុងខេត្តស្វាយរៀង ។ តំបន់សេដ្ឋកិច្ចដែលកំពុងដំណើរការនៅទូទាំងខេត្តមានចំនួន ៩កន្លែង ក្នុងនោះតំបន់សេដ្ឋកិច្ចដែលមានអាងចម្រោះទឹកមានចំនួន ០៤កន្លែង ព្រមទាំងមានទីតាំងកែច្នៃសំរាមចំនួន ២កន្លែង នៅក្រុងបាវិត ។

នៅក្នុងខេត្តមានទីលានចាក់សំរាមចំនួន ៥កន្លែង ក្នុងនោះទីលានសម្រាប់ចាក់សំណល់ផ្ទះបាយមាន ៣កន្លែង និងទីលានសម្រាប់ចាក់សំណល់ឧស្សាហកម្មមាន ២កន្លែង ។

## ១២. វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ការអភិវឌ្ឍឧស្សាហកម្មកម្ពុជាប្រកបដោយនិរន្តរភាព និងធានាបាននូវសុខដុមនីយកម្មសង្គម ជាមួយនឹងបរិស្ថាន គឺជាគោលបំណងក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខេត្តប្រកបដោយចីរភាព និងមាននិរន្តរភាព ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ។

ជាក់ស្តែងនៅក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ខេត្តស្វាយរៀង មានរោងចក្រ ចំនួន ៩៥ នៅក្នុងឆ្នាំ២០១៨ ហើយកើនឡើងដល់ ១៥៣រោងចក្រ នៅក្នុងឆ្នាំ២០២២ ដែលបង្កើតការងារជូនប្រជាពលរដ្ឋចំនួន ៥១.៧៨៨នាក់ នៅឆ្នាំ២០១៨ និងកើនឡើងដល់ ៨៥.១៤១នាក់ នៅក្នុងឆ្នាំ២០២២។ ដោយឡែក វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ក៏ត្រូវបានលើកកម្ពស់ តាមរយៈការលើកស្ទួយផលិតផលឧស្សាហកម្ម និងសិប្បកម្មកម្ពុជាឱ្យមានភាពប្រកួតប្រជែង និងផ្តល់ជំនឿទុកចិត្តដល់អ្នកប្រើប្រាស់ចំពោះផលិតផលក្នុងស្រុក ធានាការពារសុខុមាលភាពសាធារណៈ សុវត្ថិភាពបរិស្ថាន និងសង្គម។

នៅខេត្តស្វាយរៀងមានរោងចក្រផលិតទឹកស្អាតកំពុងដំណើរការ ចំនួន ០៩កន្លែង ដែលមានសមត្ថភាពផលិតទឹកស្អាតបាន ១៧.៦៨៨ ម៉ែត្រគូប/១ថ្ងៃ ដែលផ្គត់ផ្គង់ជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន ១២.០៧៨គ្រួសារ។ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ ការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ មានការកើនឡើងចំនួន ៤.៨៨៦គ្រួសារ ស្មើនឹង ៦៨%។

**១៣. ការងារពាណិជ្ជកម្ម**

អនុវត្តតាមគោលនយោបាយ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ក្នុងការជំរុញលើកម្ពស់វិស័យពាណិជ្ជកម្ម គិតមកដល់ពេលនេះ ខេត្តស្វាយរៀង មានផ្សារ ចំនួន ២០កន្លែង ក្នុងនោះផ្សាររបស់រដ្ឋមាន ១១កន្លែង និងផ្សារវិនិយោគឯកជន ០៩កន្លែង និងមានផ្សាររាត្រី ០១កន្លែង នៅក្រុងបាវិត ។ ក្រៅពីនេះ មន្ទីរពាណិជ្ជកម្ម បានធ្វើការចុះបញ្ជីក្រុមហ៊ុន សហគ្រាស តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) សរុបបានចំនួន ៩០៥ក្រុមហ៊ុន សហគ្រាស (ឆ្នាំ២០២២ បាន ១៩៦សហគ្រាស) ។ ទន្ទឹមនេះ ក្នុងរយៈពេល ៥ឆ្នាំនេះ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ចំនួន ១.៧៥៨ច្បាប់ និងបានចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី(Form D) ជូនក្រុមហ៊ុននាំចេញអំពៅស្ករ ចំនួន ២៨.១៧០តោន ស្មើនឹងទឹកប្រាក់ ១.១៩៨.៥៦០ដុល្លា ក្នុងឆ្នាំ២០២២ ។

**១៤.វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

អនុវត្តតាមច្បាប់ អនុក្រឹត្យ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា រដ្ឋបាលខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការ បានខិតខំយកចិត្តទុកដាក់ អនុវត្តការងារគ្រប់គ្រងរៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ដោយផ្តោតសំខាន់លើការងារចុះបញ្ជីដីធ្លី ការងារសំណង់ ការងារកសាងផែនទីប្រើប្រាស់ដី ផែនទីហេដ្ឋារចនាសម្ព័ន្ធ ផែនទីកំណត់ព្រំប្រទល់ឃុំ សង្កាត់ និងការងារគ្រប់គ្រងដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។

ជាក់ស្តែង គិតមកដល់ដើមឆ្នាំ ២០២២នេះ យើងបានអនុវត្តការងារសម្រេចបានលទ្ធផលសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

**ក.ការងារចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធ ៖**

- បានដំណើរការអនុវត្តក្នុងភូមិចំនួន ១១៥ភូមិ ២២ឃុំ សង្កាត់ ៨ក្រុង ស្រុក ។
- បានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ១៣៣.៧៣៧ក្បាលដី ។

**ខ.ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ៖**

- បានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ១៨.០០៨ក្បាលដី ។

**គ.ការងារសំណង់ ៖**

បានចេញលិខិតអនុញ្ញាតសាងសង់ តាមរយៈមន្ទីរ អង្គភាពច្រកចេញចូលតែមួយខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក សរុបចំនួន ១៦៧គម្រោង ។

**ឃ.ការងារដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**

បាលខេត្ត តាមរយៈគណៈកម្មការសុរិយោដីខេត្ត ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការ បានខិតខំធ្វលការសម្រុះសម្រួលដោះស្រាយករណីទំនាស់ដីធ្លី ជូនបងប្អូនប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធស្របតាមនីតិវិធីច្បាប់ លិខិតបទដ្ឋានគតិយុត្ត ។ ជាក់ស្តែងគិតតាំងពីមុនមក គណៈកម្មការសុរិយោដីខេត្ត បានទទួលពាក្យបណ្តឹងសរុបចំនួន ៦៦៦ ករណី បានដោះស្រាយបញ្ចប់ ៣៩៩ ករណី ច្រានចោលពាក្យបណ្តឹង ១៨៣ ករណី ដកពាក្យបណ្តឹងវិញ ៥៩ ករណី បញ្ជូនទៅស្ថាប័នថ្នាក់ជាតិ ១១ ករណី និងបញ្ជូនមកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ០៣ ករណី ធ្វើសេចក្តីសម្រេច ០២ ករណី ។

**ង.ការងារលំនៅឋាន និងការអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចនៅខេត្តស្វាយរៀង**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈ ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ បានសម្រេចផ្តល់គម្រោងសម្បទានដីសង្គមកិច្ច ចំនួន ០២កន្លែង នៅខេត្តស្វាយរៀង សម្រាប់សាងសង់ផ្ទះ ចែកជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ កងទ័ព និងនគរបាលជាតិ គ្រួសារយុទ្ធជនពលី មរណៈ និងប្រជាជនក្រីក្រទូទៅ ដែលមានទីតាំងដូចខាងក្រោម ៖

១.គម្រោងសម្បទានដីសង្គមកិច្ច នៅភូមិដីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក ដោយបានសាងសង់ផ្ទះ ចំនួន ៤០០ខ្នងផ្ទះ លើផ្ទៃដី ១៥៣,៦៥ហិកតា (ជំហានទី១ ចំនួន ២០០ខ្នងផ្ទះ លើផ្ទៃដី ៥៥,៣ហិកតា អនុវត្តនៅឆ្នាំ២០១៧ និងជំហានទី២ ចំនួន ២០០ខ្នងផ្ទះ លើផ្ទៃដី ៩៨,៣៥ហិកតា អនុវត្តនៅឆ្នាំ២០១៩) ។

២.គម្រោងសម្បទានដីសង្គមកិច្ច នៅឃុំត្នោត ស្រុកកំពង់រោទិ៍ និងឃុំចន្ទ្រា ស្រុកចន្ទ្រា លើផ្ទៃដី ៣០០ហិកតា ដែលកំពុងអនុវត្តការងារសាងសង់ផ្ទះ ចំនួន ១០០ខ្នងផ្ទះ ក្នុងជំហានទី១ (ឆ្នាំ២០២៣) ដោយមានការជីកស្រះទឹក ប្រឡាយ បុកអណ្តូង និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ផ្សេងៗ គាំទ្រដល់ការអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចនៅទីតាំងខាងលើ ។

**១៥. ការងារផែនការ**

បានអនុវត្តការងារជំរឿនប្រជាជនទូទៅឆ្នាំ២០១៩ បានអនុវត្តការងារជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ មានអង្គភាពសេដ្ឋកិច្ចចំនួន ២៣.៩២៨ ។ បានរៀបចំផែនការអភិវឌ្ឍន៍ខេត្ត និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ជាបន្តបន្ទាប់ ។ បានសម្ភាសន៍គ្រួសារមានសមាជិកគ្រួសារឆ្លងជំងឺកូវីដ-១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ២០ កុម្ភៈ សរុបចំនួន ២.១៤៧គ្រួសារ ។

គិតត្រឹមឆ្នាំ២០២២នេះ អត្រាភាពក្រីក្រក្នុងខេត្ត ចំនួន ២៣.៦៧៨គ្រួសារ ស្មើនឹង ១៥% ក្នុងនោះក្រ១ មានចំនួន ៨.២៨៧គ្រួសារ និងក្រ២ មានចំនួន ១៥.៣៩១គ្រួសារ ។ ផលិតផលក្នុងស្រុក (GDP) សម្រាប់មនុស្សម្នាក់ មានប្រមាណ ១.៥៩៥ ដុល្លារអាម៉េរិក ។

## ១៦. វិស័យធម្មការ និងសាសនា

នៅទូទាំងខេត្ត មានវត្តអារាមសរុបចំនួន ២៤៦វត្ត និងព្រះសង្ឃ ចំនួន ២.០៦៩អង្គ ។ ក្នុងឆ្នាំសិក្សា ២០២២នេះ មានសាលាធម្មវិន័យចំនួន ៣១កន្លែង សាលាពុទ្ធិកបឋមមានចំនួន ៣២កន្លែង និងពុទ្ធិកអនុវិទ្យាល័យមានចំនួន ០១កន្លែង មានសមណសិស្ស និងសិស្សសរុប ចំនួន ១.៦២៥អង្គ/នាក់ ។ ក្នុងចំណោម វត្តអារាម ២៤៦វត្តនៅទូទាំងខេត្ត វត្តអារាម ដែលមានព្រះវិហារសាងសង់ថ្មីល្អ ចំនួន២០១ និងមានឧបដ្ឋានសាលាថ្មី ចំនួន២០៣ ។

ផ្អែកតាមគោលនយោបាយសុខដុមនីយកម្មផ្នែកសាសនា របស់រាជរដ្ឋាភិបាល កម្ពុជា ក្រៅពីការយកចិត្តទុកដាក់លើវិស័យព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ខេត្តស្វាយរៀង ក៏នៅមានពហិរសាសនាមួយចំនួនទៀត ដូចជា គ្រីស្តសាសនា ៥៥កន្លែង ឥស្លាមសាសនា ០១កន្លែង សាសនាមហាយាន ០៣កន្លែង និងបាហៃសាសនា ០១កន្លែង ។ ទន្ទឹមនឹងនេះ វិស័យព្រះពុទ្ធសាសនា ក៏បានចូលរួមចំណែកយ៉ាងសំខាន់ផងដែរក្នុងការងារសង្គម តាមរយៈកម្មវិធីព្រះពុទ្ធសាសនាផ្សាភ្ជាប់នឹងសង្គម ការងារមនុស្សធម៌ ការងារអភិវឌ្ឍមូលដ្ឋាន ជាពិសេសនៅពេលថ្មីៗ និងបច្ចុប្បន្ននេះ បាននឹងកំពុងបន្តការចូលរួមប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយអាជ្ញាធររដ្ឋបាលខេត្ត ក្រុង ស្រុក យ៉ាងសកម្មផុលផុសផងដែរ ។

## ១៧. វិស័យរ៉ែ និងថាមពល

ខេត្តស្វាយរៀង មានប្រភពថាមពល ចំនួន ៦ គឺផលិតដោយអង្គភាព ថាមពលទិញពីប្រទេសវៀតណាម ថាមពលទិញពីអនុស្ថានីយប្រេកម្ទេស ១០០MW ថាមពលពន្លឺព្រះអាទិត្យទិញពីក្រុមហ៊ុនតាយសេង បាវិត អេសអិ ហ្សេត ខូអិលធីឌី ៥MW ថាមពលពន្លឺព្រះអាទិត្យទិញពីក្រុមហ៊ុនសាន់ស៊ាប អ៊ែសេង (ខេមបូឌា) ឯ.ក ១០MW និងថាមពលពន្លឺព្រះអាទិត្យទិញពីក្រុមហ៊ុនហ្គ្រីនស្ទែនណេប៊ិល វេនឈ័រ (ខេមបូឌា) ឯ.ក ២០MW (កំពុងរៀបចំដំណើរការ) ។

ក្រុមហ៊ុនអាជីវកម្ម មានអាជ្ញាបណ្ណផលិត និងចែកចាយអគ្គិសនីនៅក្នុងឆ្នាំ២០១៨ ចំនួន ០៤ អាជ្ញាបណ្ណ និងក្នុងឆ្នាំ២០២៣ មានអាជ្ញាបណ្ណផលិត និងចែកចាយអគ្គិសនី មានចំនួន ១៣ អាជ្ញាបណ្ណ ។ ការតបណ្តាញអគ្គិសនីចូលដល់ភូមិក្នុងឆ្នាំ២០១៨ មានចំនួន ៤៣៥/៦៩០ភូមិ ស្មើនឹង ៦៣,០៤% រីឯឆ្នាំ២០២២ ការតបណ្តាញអគ្គិសនីចូលដល់ភូមិ មានចំនួន ៦៥៨/៦៩០ភូមិ ស្មើនឹង ៩៥,៣៦% ។

## ១៨. ការងារពន្ធដារ

ក្នុងរយៈពេល ៥ឆ្នាំ សរុបចំណូលថវិកាជាតិមាន ១៥២.០១៥.០១២.៤៧៣រៀល ក្នុងនោះ ចំណូលថវិកាថ្នាក់ជាតិ មានចំនួន ៥២.៧៥៣.៤៩៣.៨៣២រៀល និងថវិកាថ្នាក់ក្រោមជាតិ មានចំនួន ៩៩.៦១៥.៥១៨.៦៤១រៀល ។ ដោយឡែកក្នុងឆ្នាំ២០២២ សរុបចំណូលថវិកាជាតិមាន ៣៧.៤០៤.២១៨.៦១៥រៀល ក្នុងនោះចំណូលថវិកាថ្នាក់ជាតិ មានចំនួន ១៣.៤០៩.៩១២.១៦៨រៀល និងថវិកាថ្នាក់ក្រោមជាតិ មានចំនួន ២៣.៩៩៤.៣០៦.៤៤៧រៀល ។

## ១៩. ការងារសាខាគយ និងរដ្ឋាករ

ប្រាក់ពន្ធអាករ និងកម្រៃប្រមូលបានក្នុងរយៈពេល ៥ឆ្នាំមាន ១.៨២៣.៦៣៥.៦៥៥.៤៣០៛ និងប្រាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋមាន ៥.៨២៣.២០៨.៨៧៦.៩០០៛ ។ ដោយឡែកប្រាក់ពន្ធដែលប្រមូលបានក្នុងឆ្នាំ២០២២ (មិនគិតពន្ធបន្ទុករដ្ឋ) មានចំនួន ៣៩៧.៦៤០.០៨០៤០០រៀល ឬស្មើនឹង ២៧២.៣៥០ដុល្លារ/ថ្ងៃ ។

## ២០. ការងារទេសចរណ៍

ខេត្តស្វាយរៀង មានរមណីយដ្ឋានទេសចរណ៍ ០៣កន្លែង ក្នុងនោះ រួមមាន រមណីយដ្ឋានធម្មជាតិព្រៃបាសាក់ ដែលមានទីតាំងស្ថិតនៅ ឃុំបាសាក់ ស្រុកស្វាយជ្រំ មានចម្ងាយពីទីរួមខេត្តប្រមាណ ៨គីឡូម៉ែត្រ ប្រាសាទជាហោ ដែលជាប្រាសាទបុរាណ ស្ថិតនៅភូមិព្រៃក្ដី ឃុំគគីរ ស្រុករមាសហែក មានចម្ងាយប្រមាណ ៥៨គីឡូម៉ែត្រ ពីទីរួមខេត្ត ព្រមទាំងមានកន្លែងកម្សាន្តទេសចរណ៍ ដែលរៀបចំដោយរដ្ឋបាលខេត្ត រួមមាន ប្រាំង និងសួនច្បារទន្លេវៃគោ ព្រឹត្តិការណ៍សង្ក្រាន្តស្វាយរៀង ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ដែលមានបងប្អូនប្រជាពលរដ្ឋ ចូលរួមកម្សាន្តសប្បាយប្រមាណជាង ៤០០.០០០នាក់ ។ នៅទូទាំងខេត្ត មានមណ្ឌលកម្សាន្ត ៣១កន្លែង ផ្ទះសំណាក់ ៥៤កន្លែង សណ្ឋាគារ ២៨កន្លែង ភោជនីយដ្ឋាន ៥២កន្លែង និងផ្សេងៗទៀត រួមមាន ផ្សាររាត្រី ០១កន្លែង មជ្ឈមណ្ឌលកម្សាន្តមនុស្សពេញវ័យ ២៨កន្លែង ។

## ២១. ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

នៅទូទាំងខេត្ត មានក្រុមហ៊ុនទូរស័ព្ទចល័តចំនួន ០៥ក្រុមហ៊ុន រួមមាន ក្រុមហ៊ុនមិត្តហ្វូន ក្រុមហ៊ុនស្មាត ក្រុមហ៊ុនសេលខាត ក្រុមហ៊ុនខូលតែល និងក្រុមហ៊ុន ស៊ីតែល និងមានទូរស័ព្ទអចល័តចំនួន ០២ ក្រុមហ៊ុន គឺសាខាទូរគមនាគមន៍កម្ពុជា និងក្រុមហ៊ុនកាំមីនតែល ។ បន្ថែមពីនេះ ក៏មានកាប្លិ៍អុបទិកកប់ក្រោមដី ចំនួន ០៣ក្រុមហ៊ុន ។

## ២២. ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសអនុសាសន៍ ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងផ្តល់ដំបូន្មានថា យើងមិនត្រូវទុកឱ្យប្រជាពលរដ្ឋណាម្នាក់មានគ្រោះថ្នាក់ ឬស្លាប់ ដោយសារយើងមិនបានយកចិត្តទុកដាក់ជួយដោះស្រាយនោះទេ រដ្ឋបាលខេត្ត ដោយមាន

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការ បានយកចិត្តទុកដាក់ អនុវត្តកម្មវិធីនានាដូចខាងក្រោម៖

**ក.ការគ្រប់គ្រង អតីតមន្ត្រីរាជការស៊ីវិល**

បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលបានកំពុងគ្រប់គ្រងនិវត្តជន ១.៩៤១នាក់ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ៧៣នាក់ គ្រួសារមរណៈ ៥៦១គ្រួសារ និងអ្នកនៅក្នុងបន្ទុកចំនួន ២.២០៣នាក់ ដែលមានប្រាក់ប្រចាំខែចំនួន ១.៤៤២.២៧៧.៩៤២ រៀលក្នុងមួយខែ។

**ខ. ការគ្រប់គ្រង អតីតយុទ្ធជន**

បេឡាជាតិរបបសន្តិសុខសង្គម សម្រាប់អតីតយុទ្ធជនបានកំពុងគ្រប់គ្រងអតីតយុទ្ធជនគ្រប់ប្រភេទចំនួន ៣.៤៣៣គ្រួសារ ក្នុងនោះមាន ជនពលី ១.០១៤គ្រួសារ ជនមរណៈ ៤៩៧ គ្រួសារ ជនពិការ ៦៣៧នាក់ និវត្តជន ១.២៣៤នាក់ ជនបាត់បង់ ៥១នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ៤.៧៥២នាក់ ដែលមានប្រាក់ប្រចាំខែចំនួន ១.៧៨៦.៥១៧.២៥១រក្នុងមួយខែ។

**គ.កម្មវិធីឧបត្ថម្ភសាច់ជូនប្រាក់គ្រួសារក្រីក្រ ក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងកូវីដ-១៩**

គិតតាំងពីចាប់ផ្តើមកម្មវិធី ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ បានចំនួន ៣៣.៧០៦គ្រួសារ ស្មើទឹកប្រាក់ ១២៣.៤២៥.០៦០.០០០រៀល។

**ឃ.កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភ ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ បានចំនួន ២៩.២២៨នាក់ ថវិកាសរុប ១.៦៥៩.៥២០.០០០រៀល។

**ង.កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា**

-លើកទី១ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ចំនួន ២១.៨២៩ គ្រួសារ ទឹកប្រាក់សរុប ២.៧៨៨.៤៨៧.៧០០ រៀល ។

-លើកទី២ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ មានចំនួន ២៤.២៩៥ គ្រួសារ ទឹកប្រាក់សរុប ៣.០៦៣.៩៦៥.៥០០ រៀល ។

**ច.កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់**

-លើកទី១ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ៨៦៩គ្រួសារ ស្មើនឹងទឹកប្រាក់ ១២៣.៦៤៨.០០០ រៀល។

-លើកទី២ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ មានចំនួន ៨៦៩គ្រួសារ ស្មើនឹងទឹកប្រាក់ ១២៣.៦៤៨.០០០ រៀល។

-លើកទី៣ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ មានចំនួន ៨៦៩គ្រួសារ ស្មើនឹងទឹកប្រាក់ ១២៣.៦៤៨.០០០រៀល ។

**ង.កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគោលនយោបាយ ជូនជនពិការមានភាពក្រីក្រតាមសហគមន៍**

បានឧបត្ថម្ភប្រាក់គោលនយោបាយជូនជនពិការមានភាពក្រីក្រតាមសហគមន៍នៅចំនួន ២.១០០នាក់ សរុបទឹកប្រាក់ចំនួន ៤៣៥.៩៦០.០០០រៀល។

**ច.គម្រោងផ្តល់ជំនួយសង្គ្រោះ**

បានផ្តល់ជំនួយសង្គ្រោះដល់ជនរងគ្រោះ និងជនងាយនឹងរងគ្រោះ ចំនួន១.៤០០គ្រួសារ។

**ឆ.កម្មវិធីអត្តសញ្ញាណកម្ម ជនមានពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន**

-បានធ្វើសម្ភាសន៍ជនមានពិការភាពចំនួន ១៧.១៦៥ នាក់ ស្រី ៨.៥៦៤ នាក់

-បានពិនិត្យនិងបញ្ជូនទិន្នន័យជនមានពិការភាពទៅក្រសួងចំនួន ១៦.៤១៧ នាក់ ស្រី ៨.១៩៦ នាក់

-ក្រសួងបានពិនិត្យ និងអនុម័តចេញប័ណ្ណជូនជនមានពិការភាពចំនួន ១៦.៤១៧នាក់ ស្រី ៨.១៩៦ នាក់

**ជ.ការងារសមាគមមនុស្សចាស់ និងសមគមអតីតយុទ្ធជន**

បានផ្សព្វផ្សាយ និងបង្កើតសមាគមមនុស្សទូទាំងខេត្ត ដែលមានសមាគមចំនួន៨០ ឃុំ សង្កាត់ មានសមាជិកចូលរួមចំនួន ២៣.៩៥១នាក់ស្រី ១៥.២៣៩នាក់។ សមាគមអតីតយុទ្ធជនកម្ពុជា ខេត្តស្វាយរៀង មានសមាជិកចំនួន ២.៨៧៥នាក់ស្រី នាក់ ក្នុងនោះ មាន គ្រួសារជនពលី ៧៧៣នាក់ គ្រួសារជនមរណៈ ២៣៦នាក់ ជនពិការ ៦៣២នាក់ និវត្តជន ១.១៨៤នាក់ និងជនបាត់បង់សមត្ថភាពការងារ ៥០នាក់។

## ២៣. ការងារព័ត៌មាន

ក្នុងខេត្តស្វាយរៀង មានស្ថានីយ៍ទូរទស្សន៍របស់រដ្ឋ ០១ស្ថានីយ វិទ្យុរបស់រដ្ឋ ០១ស្ថានីយ វិទ្យុឯកជន ០៨ស្ថានីយ ទូរសទស្សន៍ឯកជន ០៩ស្ថានីយ និងទូរទស្សន៍ ខ្សែកាប ០៦ស្ថានីយ អង្គភាពការសែតចំនួន ៣ អង្គភាពគេហទំព័រចំនួន ១៩ និងមានភ្នាក់ងារសារព័ត៌មាន ចំនួន ៩៨ភ្នាក់ងារ។

## ២៤. ការងារវប្បធម៌ និងវិចិត្រសិល្បៈ

នៅខេត្តស្វាយរៀង មានប្រាសាទបុរាណចំនួន ២ គឺប្រាសាទព្រៃបាសាក់ ស្ថិតនៅឃុំបាសាក់ ស្រុកស្វាយជ្រំ និងប្រាសាទជាហោ ស្ថិតនៅឃុំគគីរ ស្រុករមាសហែក ។ បានអភិរក្សសំណង់បុរាណ ប្រាសាទបុរាណចំនួន ២ទីតាំង និងព្រះវិហារបុរាណចំនួន ៣ទីតាំង បានរក

ឃើញ និងទទួលបានវត្ថុបុរាណ វត្ថុសិល្បៈពីគ្រប់ប្រភពសរុបចំនួន ៥ ។ វត្ថុបុរាណ វត្ថុសិល្បៈ ដែលបានចុះបញ្ជីសារពើភណ្ឌមានចំនួន ២០១ បានធ្វើសាលាកបត្រកាន់កាប់បុរាណដ្ឋានសរុប ចំនួន ២៧៩បុរាណដ្ឋាន និងបានធ្វើប្លង់ ឬប័ណ្ណកម្មសិទ្ធិរដ្ឋកាន់កាប់បុរាណដ្ឋានសរុបចំនួន ៣០៣បុរាណដ្ឋាន ព្រមទាំងបាន ធ្វើបច្ចុប្បន្នភាពបុរាណដ្ឋានសរុបចំនួន ៨០៤បុរាណដ្ឋាន ។

### ២៥. ក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តស្វាយរៀង

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅខេត្តស្វាយរៀង ដែលដឹកនាំដោយលោក ជំទាវ **កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** បានយកចិត្តទុកដាក់ចុះបំពេញការងារនៅតាមមូលដ្ឋាន តាមរយៈការធ្វើវេទិកាសាធារណៈ និងការចុះជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋដោយផ្ទាល់ សំដៅជួយសម្រួលដោះស្រាយដល់គ្រួសារប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ជួបគ្រោះ មហន្តរាយ និងគ្រួសារងាយរងគ្រោះ ។ ក្នុងឆ្នាំ២០២២ ក្រុមការងាររាជរដ្ឋាភិបាល បានធ្វើវេទិកាសា ធារណៈ ចំនួន ២០៩លើក មានប្រជាពលរដ្ឋចូលរួមចំនួន ៣៧.៦៩៨នាក់ បានទទួលសំណើ សំណូមពរថ្មី កង្វល់ សរុប ១៧៧ករណី បានឆ្លើយបំភ្លឺរួច និងបានដោះស្រាយរួចចំនួន ១១៦ ករណី កំពុងដោះស្រាយចំនួន ៤៥ករណី និងនៅសល់បញ្ជូនទៅថ្នាក់ជាតិចំនួន ១៦ ។ ក្រៅ ពីនេះ ក្រុមការងាររាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ចូលរួមក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩ បានយ៉ាងសកម្មផុលផុស ជាមួយអាជ្ញាធរដែនដី មន្ត្រីរាជការកងកម្លាំងគ្រប់ លំដាប់ថ្នាក់ផងដែរ ។

## IV. ទិសដៅការងារបន្តរបស់រដ្ឋបាលខេត្ត

1. អាជ្ញាធរខេត្ត ក្រុង ស្រុក ដែលមានគណៈបញ្ជាការឯកភាព ជាសេនាធិការ បន្ត ការខិតខំធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដោយជំរុញអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដែលមានលក្ខណៈ សម្បត្តិទាំង ៧យ៉ាង ឱ្យមានប្រសិទ្ធភាព និងបន្ត ការរៀបចំវេទិកាសាធារណៈនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានជាប់ជាប្រចាំដូចភ្លៀងរលឹម ។

2. រៀបចំអនុវត្តគម្រោងសម្បទានដីសង្គមកិច្ច នៅតាមព្រំដែន ដើម្បីចែកជូនកង ទ័ព នគរបាលឈរជើងតាមព្រំដែន អតីតកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រី ក្រស៊ីវិលទូទៅ ។

3. បន្តកិច្ចប្រតិបត្តិការបង្ក្រាបការជួញដូរមនុស្ស បង្ក្រាបល្បែងស៊ីសងខុសច្បាប់ ជនអន្តោប្រវេសន៍ខុសច្បាប់ ពិសេសលើការអនុវត្តការងារអធិការកិច្ចហត្ថពលកម្មបរទេស

4. បន្តអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល កំណែទម្រង់រដ្ឋបាល សាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិស ហមជ្ឈការ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឱ្យមានប្រសិទ្ធ

ភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម ព្រមទាំងចូលរួមអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

5. ខិតខំជំរុញការអភិវឌ្ឍខេត្ត ឱ្យសម្រេចបានលទ្ធផលល្អ ស្របតាមផែនការអភិវឌ្ឍន៍ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ។

6. បន្តការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការអនុវត្តមុខងារ តួនាទីភារកិច្ច ក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ស្របតាមគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម ។

7. ពង្រឹងការអនុវត្តការងារ របស់អង្គភាពច្រកចេញចូលតែមួយខេត្ត និងការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ឃុំ សង្កាត់ ឱ្យមានដំណើរការល្អ ក្នុងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

8. ជំរុញគម្រោងវិនិយោគនានា ជាពិសេសគម្រោងអភិវឌ្ឍន៍គុណប្រយោជន៍ខេត្ត គម្រោងមូលនិធិអភិវឌ្ឍន៍ក្រុង ស្រុក ឃុំ-សង្កាត់ ឱ្យសម្រេចបានលទ្ធផលល្អ ធានាបានទាំងបរិមាណ និងគុណភាព ដើម្បីផលប្រយោជន៍សាធារណៈ ។

9. បន្តពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ និងការអភិវឌ្ឍធនធានមនុស្ស និង ស្ថាប័នដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផល ។

10. បន្តយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន និងទទួលយកនូវសំណើ សំណូមពររបស់ប្រជាពលរដ្ឋ ជាពិសេសបញ្ហាទំនាស់ដីធ្លី និងវិវាទនានានៅមូលដ្ឋាន ដោយផ្អែកតាមនីតិវិធីច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន ។

11. ពង្រឹងការអនុវត្តតួនាទីភារកិច្ច របស់មន្ត្រីរាជការ ឱ្យមានទឹកចិត្តស្រឡាញ់ការងារប្រកប ដោយភាពស្វាហាប់ និងប្រកាន់ភ្ជាប់នូវឥរិយាបថមន្ត្រីរាជការ គឺ ឆន្ទៈម្ចាស់ការភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ដោយផ្អែកលើអភិក្រមទាំង៥ គឺ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ដើម្បីបង្កើនការជឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ។

12. បន្តជំរុញការងារបង្កបង្កើនផល ការងារផលិតកម្មកសិកម្ម ដោយផ្តល់ជំនាញបច្ចេកទេស កសិកម្មដល់ប្រជាកសិករ ជាពិសេសជំរុញការប្រឡងប្រណាំងចលនាភូមិមួយផលិតផលមួយ ។

13. អនុវត្តគម្រោងស្តារព្រែកនៀល ប្រវែង ១៤,១១គ.ម ដែលហូរកាត់ចាប់ពីក្រុងស្វាយរៀង ស្រុកស្វាយជ្រំ និងស្រុកកំពង់រោទិ៍ និងសាងសង់ប្រព័ន្ធធារាសាស្ត្រផ្សេងៗទៀតនៅក្នុងខេត្ត ។

14. បន្តទប់ស្កាត់ និងចាត់វិធានការច្បាប់ ចំពោះការចាក់ដីរំលោភបំពានដីអាងព្រែក បឹង អូរ ធម្មជាតិ ធ្វើជាកម្មសិទ្ធិឯកជន និងសហការជំរុញការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ និងពង្រឹងយន្តការ នៃការគ្រប់គ្រងដីរដ្ឋ ឱ្យមានប្រសិទ្ធភាព ។

15. បន្តការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស និងទប់ស្កាត់សំណង់អនាធិបតេយ្យ និងសំណង់គ្មានលិខិតអនុញ្ញាត ។

16. ជំរុញឱ្យអាជ្ញាធរក្រុង ស្រុក ឱ្យរៀបចំទីកន្លែងសម្រាប់ចាក់សំរាម និងសំណល់ផ្សេងៗឱ្យបានត្រឹមត្រូវ ។

17. បន្តពង្រីកបណ្តាញអគ្គិសនីជូនប្រជាពលរដ្ឋប្រើប្រាស់ឱ្យបានគ្រប់ភូមិ ។

18. បង្កើនការយកចិត្តទុកដាក់ លើគុណភាពសេវាសុខាភិបាលនៅតាមបណ្តាមន្ទីរពេទ្យ មណ្ឌលសុខភាព និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈគ្រូពេទ្យ ។

19. ពង្រឹងគុណភាពអប់រំ និងយកចិត្តទុកដាក់ទប់ស្កាត់ការបោះបង់ការសិក្សា របស់សិស្ស ។

20. ជំរុញចលនាប្រឡងប្រណាំង «ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និង បដិសណ្ឋារកិច្ចល្អ» ។

21. បន្តការចុះផ្សព្វផ្សាយវិធានការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងផ្តល់ការផ្តល់ណែនាំពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

22. បន្តជំរុញការគាំទ្រ និងតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំ នៃគ្រួសារក្រីក្រ ព្រមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

23. បន្តចុះអប់រំ និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋ អំពីអនាម័យសុខភាព ការប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យនៅមូលដ្ឋាន ។

24. បន្តជួសជុលផ្លូវជនបទដោយក្រាលកៅស៊ូ ក្រាលខ្សាច់ក្រួស និងការថែទាំផ្លូវជាលក្ខណៈខួប និងការថែទាំផ្លូវប្រចាំ ។

25. បន្តខិតខំទាក់ទាញក្រុមហ៊ុន អ្នកវិនិយោគឯកជន ឱ្យមកបណ្តាក់ទុនវិនិយោគទុនក្នុងខេត្តឱ្យកាន់តែច្រើនថែមទៀត ដើម្បីបង្កើតការងារ ជូនប្រជាពលរដ្ឋ ។

26. ជំរុញផ្សព្វផ្សាយ អំពីការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ដើម្បីផ្តល់ជំនាញដល់ប្រជាពលរដ្ឋដើម្បីងាយស្រួលក្នុងការរកការងារធ្វើ ក៏ដូចជាបង្កើតមុខរបរផ្ទាល់ខ្លួនបង្កើនប្រាក់ចំណូលគ្រួសារ ។

27. ជំរុញលើកទឹកចិត្ត និងផ្តល់បច្ចេកទេសកសិកម្ម សំដៅលើកកម្ពស់ការងារផលិតកម្មពិពិធកម្មកសិកម្ម ដល់ប្រជាកសិករ ដើម្បីធ្វើការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ ជួយសម្រួលដោះស្រាយការងារធ្វើនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

28. បន្តគាំទ្រ និងជំរុញការសាងសង់រោងចក្រ អាងចម្រោះទឹកស្អាត ស្ថានីយ៍បូមទឹក និងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងស្វាយរៀង ដែលមានប្រវែង បណ្តាញ ៣០ គីឡូម៉ែត្រ មានសមត្ថភាពផលិតទឹកស្អាតបាន ១៨.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលជាគម្រោងរបស់ ADB និងគម្រោងរបស់ JICA ។